មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# វិធានការ និងចំណាត់ការសំខាន់ៗ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការឆ្លើយតបនឹងជំងឺកូវីដ១៩ (COVID-19) ក្នុងឆ្នាំ២០២១

*ត្រឹមថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១៦:០០ រសៀល*

| កាលបរិច្ឆេទ | | វិធានការ និងចំណាត់ការ |
|---|---|---|
| មីនា ២០២១ | ថ្ងៃទី៩ | សារសំឡេងសម្តេចតេជោនាយករដ្ឋមន្ត្រី៖<br>- សម្រេចថា ករណីអ្នកដែលមានជំងឺកូវីដ១៩ ទទួលមរណភាព ត្រូវតែធ្វើការបូជាជាចាំបាច់ ព្រោះយើងមិនមានដីកប់សពនីមួយៗនោះទេ និងដើម្បីជានានូវវិធានការមួយសម្រាប់ការគ្រប់គ្រងដីធ្លី និងការដាក់សព ហើយវិធានការបូជា ជាវិធានការដែលងាយស្រួលក្នុងការគ្រប់គ្រង។<br>- បានប្រើវិធានការបូជា សម្រាប់ជនជាតិចិនម្នាក់ដែលបានទទួលមរណភាព។<br>- ស្នើទៅកាន់គ្រប់រាជធានី-ខេត្តនានា ចាត់វិធានការរៀបចំ ក្នុងករណីមានការទទួលមរណភាព ដោយប្រើប្រាស់នូវបញ្ចាដែលមានស្រាប់ និងត្រូវរៀបចំបញ្ចាមួយសមរម្យ និងធ្វើនៅឆ្ងាយពីប្រជាពលរដ្ឋ។<br>- ស្នើរៀបចំអនុក្រឹត្យមួយ ទាក់ទងការបូជាសពនៃអ្នកដែលមានជំងឺកូវីដ១៩ ដោយមានកំណត់ចំនួនមនុស្សចូលរួម។ |
| | | សេចក្តីណែនាំបន្ថែមរបស់ក្រសួងផែនការ ស្តីពី វិធានការបន្ទាន់ក្នុងការទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ ក្នុងសហគមន៍ទ្រង់ទ្រាយធំ |
| | | សេចក្តីជូនដំណឹងរបស់អគ្គលេខាធិការដ្ឋានរដ្ឋសភា ស្តីពី ការរឹតបន្តឹងវិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ១៩ នៅក្នុងបរិវេណវិមានរដ្ឋសភា |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការផ្អាកដំណើរការសិក្សានៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាបណ្តោះអាសន្ននៅខេត្តព្រៃវែង ខេត្តកំពង់ចាម និងខេត្តកោះកុង |
| | | រដ្ឋបាលខេត្តកណ្តាល ជម្រាបមកអភិបាល នៃគណៈអភិបាលស្រុកកោះធំ ស្តីពី ការបិទជាបណ្តោះអាសន្ន ចំពោះកាស៊ីណូ និងបិទការធ្វើដំណើរចេញចូល នៅតំបន់ទីប្រជុំជនជ្រៃធំ ស្ថិតក្នុងឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល។ |
| | | សេចក្តីណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពី ការចាត់វិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ១៩ |
| | | រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ធ្វើការណែនាំ និងដាក់ចេញនូវវិធានការចាំបាច់ និងបន្ទាន់ ដើម្បីធានាបានជាអតិបរមានូវសុវត្ថិភាពរួមរបស់មន្ត្រីរាជការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅចំពោះមុខស្ថានភាពព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ។ |
| | | សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ការប្រារព្ធទិវាជាតិអំណាន ១១ មីនា ២០២១ លើកទី៦ តាមអនឡាញ |
| | | រដ្ឋបាលរាជធានីភ្នំពេញ ចេញផ្សាយតារាងទីតាំងអនុញ្ញាតបើកដំណើរការឡើងវិញ ក្នុងព្រឹត្តិការណ៍សហ-គមន៍ ២០កុម្ភៈ ចំនួន ២៣ទីតាំង |
| | ថ្ងៃទី៨ | ប្រជាពលរដ្ឋចំនួន ១៦៧.៤៨៧នាក់ នៅកម្ពុជា បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ គិតត្រឹមថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១។ |

© រក្សាសិទ្ធគ្រប់យ៉ាងដោយ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា ឆ្នាំ២០២១

| | | |
|---|---|---|
| មីនា ២០២១ | ថ្ងៃទី៨ | សារសំឡេងសម្តេចតេជោនាយករដ្ឋមន្ត្រី ផ្ញើជូនជនរួមជាតិ ពាក់ព័ន្ធស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា ដែលបាននិងកំពុងរីករាលដាលខ្លាំងឡើងៗ៖<br>- សុំផ្អាកជាបណ្តោះអាសន្ន ក្នុងរយៈពេលយ៉ាងតិច ៧ថ្ងៃ នូវស្ថាប័នរបស់រាជរដ្ឋាភិបាល និងស្ថាប័ននីតិបញ្ញត្តិ ដោយមានមនុស្សតិចតួចនៅប្រចាំការ កាត់បន្ថយចំនួនមនុស្សយ៉ាងតិចតិច ៩០ភាគរយ។<br>- អំពាវនាវវិស័យឯកជន បើអាចធ្វើទៅបាន កាត់បន្ថយចំនួនបុគ្គលិកផ្លាស់ប្តូរវេនគ្នាទៅធ្វើការ។<br>- អំពាវនាវដល់ក្រុមគ្រួសារ បើមិនមានការចាំបាច់ កុំចេញក្រៅផ្ទះ។<br>- ស្នើព្រឹទ្ធសភាពិនិត្យ និងដាក់ឱ្យប្រើប្រាស់ច្បាប់គ្រប់គ្រងទាក់ទងនឹងជំងឺកូវីដ១៩។<br>- អំពាវនាវផ្អាកការជួបជុំដែលមិនចាំបាច់ ឬពន្យារពេលក្នុងការធ្វើ។<br>- ខេត្តព្រះសីហនុបង្កើនការរឹតត្បិត ការចេញចូលរបស់មនុស្ស ប៉ុន្តែកុំឱ្យមានការរាំងស្ទះការដឹកជញ្ជូនទំនិញចេញចូល។<br>- កងកម្លាំង និងក្រុមពេទ្យ គឺនៅតែបន្តប្រតិបត្តិការ។<br>- មិនទាន់តម្រូវឱ្យមានការបិទ ឬផ្អាកដំណើរការរោងចក្រ ផ្សារ និងអាជីវកម្មផ្សេងៗ ក៏ប៉ុន្តែត្រូវអនុវត្តវិធានការអនាម័យឱ្យបានហ្មត់ចត់។<br>- មិនទាន់ទៅដល់ការបិទខេត្តព្រៃវែងទេ ក៏ប៉ុន្តែសូមអភិបាលខេត្តព្រៃវែងពិនិត្យស្ថានភាព តើគប្បីគួរបិទសាលារៀននៅតំបន់ដែលឆ្លងនោះដែរឬទេ។<br>- អំពាវនាវបងប្អូនប្រជាពលរដ្ឋមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច។ |
| | | សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី ការធ្វើតេស្តស្រាវជ្រាវរកករណីវិជ្ជមានជំងឺកូវីដ១៩ សម្រាប់អ្នកដែលមានការពាក់ព័ន្ធទៅនឹងទីតាំងម៉ាស្សា ០៣កន្លែង នៅរាជធានីភ្នំពេញ និងការដាក់ចេញនូវវិធានការចាំបាច់ សម្រាប់ទប់ស្កាត់ការចម្លងក្នុងទ្រង់ទ្រាយធំនៅក្នុងប្រទេសកម្ពុជា |
| | | សេចក្តីក្រើនរំឭករបស់ក្រសួងសុខាភិបាល ស្តីពី ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ ជាបន្ត សម្រាប់ក្រុមអាយុ ១៨ ទៅ ៥៩ឆ្នាំ ចាប់ពីថ្ងៃ៨ ខែមីនា ឆ្នាំ២០២១ |
| | | សេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តកំពង់ចាម ពាក់ព័ន្ធនឹងការរកឃើញករណីវិជ្ជមានកូវីដ១៩ បុរសជនជាតិខ្មែរម្នាក់ រស់នៅភូមិអូរកណ្តោ ឃុំព្រែកក្របៅ ស្រុកកងមាស ខេត្តកំពង់ចាម ធ្វើការជាគ្រូបង្រៀនម៉ាស្សា នៅសណ្ឋាគារសីញជីងថៃ នៅកែងLV ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ |
| | | រដ្ឋបាលខេត្តព្រះសីហនុ ជម្រាបពីការផ្អាកជាបណ្តោះអាសន្ន និងដាក់ជាមណ្ឌលចត្តាឡីស័ក សណ្ឋាគារស៊ីនយីនថៃ ស្ថិតនៅវិថីឯករាជ្យ (ផ្លូវលេខ១០០) ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ។ |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ការផ្អាកដំណើរការអាជីវកម្មក្លឹបហាត់ប្រាណ និងការលេងកីឡា ឬការហាត់ប្រាណគ្រប់ប្រភេទ ដែលមានលក្ខណៈប្រមូលផ្តុំជាបណ្តោះអាសន្ន នៅរាជ-ជានីភ្នំពេញ ខេត្តកណ្តាល ខេត្តព្រះសីហនុ និងខេត្តដែលមានការពាក់ព័ន្ធ |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ការផ្អាកដំណើរការគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ជាបណ្តោះអាសន្ន នៅស្រុកពាមរក៍ ខេត្តព្រៃវែង |
| | | សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ការរឹតបន្តឹងវិធានការបង្ការ និងទប់ស្កាត់ការពតត្បាតនៃជំងឺកូវីដ១៩ នៅតាមអង្គភាពថ្នាក់ជាតិ |
| | ថ្ងៃទី៧ | សេចក្តីជូនដំណឹងរបស់ក្រសួងសុខាភិបាល ស្តីពី ការដាក់ឱ្យដំណើរការប្រើប្រាស់អាគារនៃសណ្ឋាគារ THE GREAT DUKE (អតីតសណ្ឋាគារអាំងទែកុងទីណង់តាល់) ធ្វើជាមន្ទីរពេទ្យពិនិត្យថែទាំ និងព្យាបាលអ្នកជំងឺកូវីដ១៩ កម្រិតស្រាល |
| | | សេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តព្រៃវែង ស្តីពី ករណីវិជ្ជមានកូវីដ១៩ នៃម្ចាស់មន្ទីរសម្រាកព្យាបាល និងសម្ភពអ៊ឹម សុភី |
| | | សេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្តកំពង់ធំ ពាក់ព័ន្ធនឹងការរកឃើញករណីវិជ្ជមានកូវីដ១៩ ជនជាតិខ្មែរម្នាក់ ភេទស្រី រស់នៅភូមិគីរីអែណ្តែត ឃុំទ្រៀល ស្រុកតាំងគោក ខេត្តកំពង់ធំ |

| | | |
|---|---|---|
| មីនា ២០២១ | ថ្ងៃទី៧ | សារសំឡេងសម្តេចតេជោនាយករដ្ឋមន្ត្រីៈ<br>- សម្រេចបញ្ចប់ការធ្វើចត្តាឡីស័កនៅតាមព្រំដែនកម្ពុជា-ថៃ ចំពោះបុគ្គលដែលគ្មានការសង្ស័យ។<br>- សូមបញ្ជាក់ សូមដឹកជញ្ជូនទាំងអ្នកដែលកំពុងធ្វើចត្តាឡីស័កនៅតាមមណ្ឌលចត្តាឡីស័ក និងអ្នកដែលទើបចូលមកដល់ថ្មីទៅតាមបណ្តាខេត្តរបស់គាត់។<br>- សម្រាប់អ្នកអវិជ្ជមាន បញ្ជូនពួកគាត់មកខាងក្រោយ ទាំងអ្នកកំពុងធ្វើចត្តាឡីស័ក និងអ្នកមកដល់ថ្មី ត្រូវដឹកជញ្ជូនទៅតាមបណ្តាខេត្តរបស់ពួកគាត់ ហើយប្រគល់ឱ្យខេត្តនៅខាងក្នុងទទួលខុសត្រូវឱ្យពួកគាត់បន្តធ្វើចត្តាឡីស័ក។<br>- ស្នើខេត្តបណ្តាខេត្តខាងក្រោយ (បណ្តាខេត្តផ្ទៃក្នុងប្រទេស) បញ្ជូនតំណាងទៅកាន់បណ្តាខេត្តខាងមុខ ដើម្បីទទួលយកអ្នកដែលត្រូវមកកាន់ខេត្តរបស់ខ្លួនវិញ និងដើម្បីចៀសវាងការគេចវេសពីការធ្វើចត្តាឡីស័ក។<br>- ចេញបញ្ជាឱ្យអគ្គបញ្ជាការ ក៏ដូចជាបញ្ជាការជើងគោក និងក្រសួងការពារជាតិ បញ្ចេញរថយន្តទៅដឹកបងប្អូនទៅកាន់គោលដៅតាមខេត្ត។ អគ្គស្នងការនគរបាលជាតិ បើអាចធ្វើទៅបាន ក៏ត្រូវរួមចំណែក ប្រើប្រាស់កម្លាំងរថយន្ត ដឹកជញ្ជូនក្នុងមួយរយៈពេលខ្លី។ មិនអនុញ្ញាតឱ្យធ្វើដំណើរតាមរថយន្តឯកជន និងរថយន្តតាក់ស៊ីនោះទេ។ |
| | | សេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្តព្រះសីហនុ ស្តីពី ការគិតគូររៀបចំវិធីចុះឈ្មោះនៅតាមសាលាឃុំសង្កាត់ ដើម្បីមានភាពងាយស្រួលដល់បងប្អូនប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចុះឈ្មោះចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ |
| | | សេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្តព្រះសីហនុ ស្តីពី ការប្តូរទីតាំងរកសំណាកតេស្តរកកូវីដ១៩ មកកាន់ទីតាំងថ្មី វេទិកា ៧មករា |
| | | រដ្ឋបាលខេត្តព្រះសីហនុ ជម្រាបពីការផ្អាកជាបណ្តោះអាសន្ន និងដាក់ជាមណ្ឌលចត្តាឡីស័ក ក្លឹបអន្តរជាតិជូហាវ និងផ្ទះនៅខាងក្រោយក្លឹប ស្ថិតនៅវិថីសន្តិភាព ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ។ |
| | ថ្ងៃទី៦ | សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ សម្រាប់ក្រុមអាយុ ៦០ឆ្នាំ ឡើង ចាប់ពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ |
| | | សេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្តព្រះសីហនុ ស្តីពី ការចុះឈ្មោះចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ |
| | | រដ្ឋបាលខេត្តព្រះសីហនុ ជម្រាបពីការផ្អាកជាបណ្តោះអាសន្ន និងដាក់ជាមណ្ឌលចត្តាឡីស័ក ផ្ទះជួលនៅជាប់ និងនៅពីក្រោយក្រុមហ៊ុនផលិតស្លាកយីហោហ៍ស៊ីន ស្ថិតនៅវិថីអូរត្រេះ ភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ។ |
| | ថ្ងៃទី៥ | សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី កម្មវិធីចាក់វ៉ាក់សាំងកូវីដ១៩ ជាបន្ត ចាប់ពីថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១ |
| | | សេចក្តីជូនដំណឹងរដ្ឋបាលខេត្តស្វាយរៀង ស្តីពី ការយកឈ្មោះ លេខទូរស័ព្ទ ថតអត្តសញ្ញាណប័ណ្ណ និងថតរូប អ្នកធ្វើដំណើរតាមរថយន្តឈ្នួលទាំងអស់ទុក ដើម្បីបង្កលក្ខណៈងាយស្រួលដល់ក្រុមការងារស្រាវជ្រាវ និងតាមដានបុគ្គលសង្ស័យមានផ្ទុកជំងឺកូវីដ១៩ នៃខេត្តស្វាយរៀង ធ្វើការស្រាវជ្រាវ និងតាមដានស្វែងរកបុគ្គលសង្ស័យមានផ្ទុកជំងឺកូវីដ១៩ អ្នកពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោល |
| | | សេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តព្រះសីហនុ ស្តីពី ការអញ្ជើញបងប្អូនដែលមានរោគសញ្ញាជំងឺកូវីដ១៩ និងធ្លាប់មានទំនាក់ទំនងជិតដិត ជាពិសេសម្ចាស់រថយន្តតាក់ស៊ី ដែលទាក់ទងនឹងករណីបុរសជនជាតិចិន ស្នាក់នៅសណ្ឋាគារឡាយអឹងហាយ មកធ្វើតេស្តសំណាក |
| | | រដ្ឋមន្ត្រីក្រសួងសុខាភិបាល គោរពជូនរដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ស្តីពី ករណីសំណើផ្តល់អាទិភាពចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ តាមគោលការណ៍ស្ម័គ្រចិត្តដល់មន្ត្រីរាជការ និងបុគ្គលិក ដែលពាក់ព័ន្ធផ្តល់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស។ |
| | ថ្ងៃទី៤ | សេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្តព្រះសីហនុ ស្តីពី ការអនុវត្តតាមការណែនាំដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩ ទៅក្នុងសហគមន៍ |

| | | |
|---|---|---|
| មីនា ២០២១ | ថ្ងៃទី៤ | សម្តេចតេជោនាយករដ្ឋមន្ត្រី អញ្ជើញធ្វើសន្និសីទសារព័ត៌មាន ក្រោយទទួលការចាក់វ៉ាក់សាំងកូវីដ១៩៖<br>- កម្ពុជាអាចមានលទ្ធភាពក្នុងការទទួលបានជំនួយវ៉ាក់សាំងស៊ីណូហ្វាម (Sinopharm) ពីចិនលើសពី១លានដូស ខណៈចំនួន ៤០ម៉ឺនដូស បន្ថែម នឹងមកដល់កម្ពុជាមុនចូលឆ្នាំខ្មែរខាងមុខ។<br>- សូមបញ្ជាក់ជាថ្មី អំពីមូលហេតុដែលសម្តេចមិនអាចចាក់វ៉ាក់សាំងស៊ីណូហ្វាមរបស់ចិន ដោយសារតែកត្តាអាយុដែលកំណត់គឺ ១៨ឆ្នាំ ដល់ ៥៩ឆ្នាំ ហើយវ៉ាក់សាំងថ្មីឈ្មោះ អាស្ត្រាហ្សេនីកា (AstraZeneca) មិនមានការកំណត់អាយុនោះទេ។<br>- ថ្លែងអំណរគុណដល់ដៃគូអន្តរជាតិនានា ដែលបានជួយសម្រួបសម្រួលក្នុង ការផ្តល់ជំនួយវ៉ាក់សាំងដល់ប្រទេសកម្ពុជា។ ប្រទេសកម្ពុជាជាប្រទេសទី១ នៅអាស៊ីប៉ាស៊ីហ្វិក ដែលទទួលបានវ៉ាក់សាំងពីមជ្ឈមណ្ឌលកូវ៉ាក់ (COVAX Facility) នាពេលនេះ។<br>- នៅពេលខាងមុខ កម្ពុជានឹងអាចនឹងទទួល វ៉ាក់សាំង២០ភាគរយ នៃចំនួនប្រជាពលរដ្ឋ ពីមជ្ឈមណ្ឌលកូវ៉ាក់ ប៉ុន្តែការទទួលនេះ នឹងធ្វើឡើងតាមដំណាក់កាលដែលឆមាសទី១ កម្ពុជានឹងបានជាង១លានដូស និងដំហានបន្តបន្ទាប់ទៀត។<br>- ស្នើក្រសួងសុខាភិបាលរៀបចំចាក់វ៉ាក់សាំង AstraZeneca ជូនប្រជាពលរដ្ឋទូទៅដែលមានអាយុចាប់ពី៦០ឆ្នាំឡើង ជំហានដំបូងអាទិភាពសំខាន់ គឺខេត្តក្រុងគោលដៅចំនួនបីគឺ រាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ ដែលជាខេត្តក្រុងប្រឈមនឹងការរីករាលដាលជំងឺកូវីដ១៩។<br>- ការរក្សាទុកវ៉ាក់សាំង Sinopharm មានរយៈពេល ១ឆ្នាំ នឹងផុតកំណត់ ចំណែកវ៉ាក់សាំង AstraZeneca មានរយៈពេលត្រឹម ៩ខែ ប៉ុណ្ណោះ នឹងហួសពេលកំណត់ហើយ។<br>- អនុញ្ញាតឱ្យមន្ត្រីទូត ដៃគូអភិវឌ្ឍ អង្គការ សង្គមស៊ីវិល ដែលកំពុងបម្រើការងារ និងរស់នៅក្នុងប្រទេសកម្ពុជាអាចទទួលបានវ៉ាក់សាំង AstraZeneca នៅកម្ពុជាបាន ដោយឥតគិតថ្លៃ។<br>- មន្ត្រី និងប្រជាពលរដ្ឋទូទៅ ដែលមានអាយុចាប់ពី៦០ឆ្នាំឡើងលើ នឹងផ្តល់លទ្ធភាពឱ្យចាក់វ៉ាក់សាំង AstraZeneca ចំណែកអ្នកអាយុ៥៩ឆ្នាំ ចុះក្រោម អនុញ្ញាតឱ្យចាក់វ៉ាក់សាំង Sinopharm។<br>- ការចាក់វ៉ាក់សាំងមិនមែនជាដំណោះស្រាយក្នុងការ លុបបំបាត់កូវីដ១៩ពីកម្ពុជានោះទេ ប៉ុន្តែត្រូវបូករួមជាមួយនឹងវិធានការ ០៣កុំ និង០៣ការពារ ថែមទៀត ទើបជាដំណោះស្រាយដ៏ល្អ និងមានប្រសិទ្ធភាព។ រហូតមកដល់ពេលនេះ មិនមានប្រភពណាបញ្ជាក់ច្បាស់ថា ការចាក់វ៉ាក់សាំងនឹងមានប្រសិទ្ធភាពការពារ ក្នុងរយៈពេលណាមួយ ឬមួយជីវិតនោះទេ ដូច្នេះមានតែវិធីការពារអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាលតែប៉ុណ្ណោះ ទើបល្អប្រសើរ។<br>- ក្រៅពីវ៉ាក់សាំង Sinopharm និង AstraZeneca កម្ពុជាកំពុងពិនិត្យមើលវ៉ាក់សាំងប្រភេទផ្សេងៗមួយចំនួនទៀតផងដែរ រួមទាំង Johnson & Johnson របស់សហរដ្ឋអាមេរិក។<br>- អំពាវនាវដល់ប្រជាពលរដ្ឋ កុំធ្វើដំណើរចេញចូលខេត្តព្រះសីហនុ បើមិនចាំបាច់នោះទេ និងអំពាវនាវដល់ពលរដ្ឋខេត្តព្រះសីហនុ កុំចេញឆ្លងខេត្តដទៃទៀតក្នុងមួយរយៈពេលនេះ។<br>- សម្រេចផ្អាកការធ្វើដំណើររបស់ប្រជាពលរដ្ឋ ទេសចរណ៍ចូលខេត្តព្រះសីហនុ។ ប៉ុន្តែការដឹកទំនិញចេញចូលនៅ ប្រព្រឹត្តដដែល និងបានបន្តអំពាវនាវជាថ្មីឱ្យប្រជាពលរដ្ឋនៅភ្នំពេញ កុំចេញពីផ្ទះបើសិនជាគ្មានភាពចាំបាច់នោះទេ។<br>- ឯកភាពជាមួយសំណើ ក្រសួងអប់រំ យុវជន និងកីឡា ឱ្យបិទសាលារៀន នៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ មួយរយៈបន្តទៀត។<br>- អនុញ្ញាតឱ្យនិស្សិតកម្ពុជាសិក្សានៅបរទេសទទួលបានវ៉ាក់សាំងជាអាទិភាព ក្រោមគោលការណ៍ស្ម័គ្រចិត្ត។ |
| | | រដ្ឋមន្ត្រីក្រសួងសុខាភិបាល គោរពរាយការណ៍ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អំពីករណីមរណភាពរបស់បុរសជនជាតិចិនម្នាក់ ក្នុងអំឡុងពេលទទួលការព្យាបាលជំងឺកូវីដ១៩ នៅក្នុងមណ្ឌលព្យាបាលកូវីដ១៩ ព្រែកព្នៅ រាជធានីភ្នំពេញ។ |

| | | |
|---|---|---|
| មីនា ២០២១ | ថ្ងៃទី៤ | សេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តព្រះសីហនុ ស្តីពី ការអញ្ជើញបងប្អូនដែលមានរោគសញ្ញាជំងឺកូវីដ១៩ និងអាជីវករលក់ដូរ ព្រមទាំងអ្នកដែលបានចេញចូលទីតាំងហាងលក់គ្រឿងអគ្គិសនី ស្ថិតក្នុងសណ្ឋាគារ មីង ហួយ (Min Hui) ផ្សារក្តាម និងផ្សារពាណិជ្ជកម្ម មកធ្វើតេស្តសំណាក |
| | | រដ្ឋបាលខេត្តព្រះសីហនុ ជម្រាបពីការផ្អាកជាបណ្តោះអាសន្ន និងដាក់ជាមណ្ឌលចត្តាឡីស័ក៖<br>- ធនាគាររួយលី (RUI LI Bank) ផ្លូវ ២ធ្នូ ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ<br>- សណ្ឋាគារ និងផ្ទះល្វែងរ៉ុងកាង (RONG GANG GONG YU) ផ្លូវបេតុង ភូមិ១ សង្កាត់លេខ៣<br>- ហាងស៊ុបឆុងឈីង កោះឡោជីវ ផ្លូវពូឡូវ៉ៃ ភូមិ៤ សង្កាត់លេខ៤ |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ការបន្តផ្អាកដំណើរការគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន នៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងក្រុងព្រះសីហនុ ស្រុកស្ទឹងហាវ នៃខេត្តព្រះសីហនុ រហូតដល់ចប់ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារ ស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៥២) |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារ ស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៥១) |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ស្តីពីការបន្តបិទដំណើរការជាបណ្តោះអាសន្ន រោងភាពយន្ត រោងសម្តែងសិល្បៈ និងសារមន្ទីរ នៅក្នុងរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ |
| | | សេចក្តីជូនដំណឹងរបស់បេឡាជាតិសន្តិសុខសង្គម ស្តីពី ការផ្អាកដំណើរការធ្វើប័ណ្ណសមាជិក ប.ស.ស. នៅបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ដែលមានទីតាំងនៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ និងខេត្តស្វាយរៀង |
| | ថ្ងៃទី៣ | សេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តព្រះសីហនុ ស្តីពី ការអញ្ជើញបងប្អូនដែលមានរោគសញ្ញាជំងឺកូវីដ១៩ និងធ្លាប់មានទំនាក់ទំនងជិតដិត ជាពិសេសម្ចាស់រថយន្តឈ្នួល និងម៉ូតូកង់បី ដែលទាក់ទងនឹងករណីដូចខាងក្រោម មកធ្វើតេស្តសំណាក៖<br>- ស្ត្រីជនជាតិចិនម្នាក់ ស្នាក់នៅបន្ទប់លេខ១១០៣ សណ្ឋាគារជ្រើនប៉ី៣<br>- ស្ត្រីជនជាតិចិនម្នាក់ ស្នាក់នៅបន្ទប់លេខ១២០ សណ្ឋាគារហ៉េងហ្គ័នដាយឺ<br>- បុរសជនជាតិចិនម្នាក់ ស្នាក់នៅបន្ទប់លេខ៣០៣៨ សណ្ឋាគារហ្គូដដេស អ៊ែនលីបើធី និងមិត្តភក្តិរបស់គាត់ចំនួនបីនាក់ទៀត<br>- ស្ត្រីជនជាតិចិនម្នាក់ ស្នាក់នៅ Win Future ខុនដូ-អាជីវកម្ម<br>- ស្ត្រីជនជាតិចិនម្នាក់ ស្នាក់នៅបន្ទប់លេខ១៦០៦ សណ្ឋាគារជូហៃតាង<br>- បុរសជនជាតិចិនម្នាក់ ស្នាក់នៅសណ្ឋាគារជូហៃតាង (ផ្លូវឡើងវត្តលើ)<br>- ស្ត្រីជនជាតិចិនម្នាក់ ស្នាក់នៅបន្ទប់លេខ៥២៣ សណ្ឋាគារហាយជឺកាង<br>- បុរសជនជាតិចិនម្នាក់<br>- ស្ត្រីជនជាតិចិនម្នាក់ ស្នាក់នៅសណ្ឋាគារហ្គូដដេស អ៊ែនលីបើធី<br>- ស្ត្រីជនជាតិចិនម្នាក់ ស្នាក់នៅបន្ទប់លេខ៩០២២ សណ្ឋាគារហ្គូដដេស អ៊ែនលីបើធី។ |
| | | រដ្ឋបាលខេត្តព្រះសីហនុ ជម្រាបពីការផ្អាកជាបណ្តោះអាសន្ន និងដាក់ជាមណ្ឌលចត្តាឡីស័ក សណ្ឋាគារយៀកឡាយ (YUELAI HOTEL)។ |
| | | សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងកម្មវិធីចាក់វ៉ាក់សាំងកូវីដ១៩ |
| | | សេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តស្វាយរៀង ស្តីពី ករណីវិជ្ជមានជំងឺកូវីដ១៩ ក្នុងខេត្តស្វាយរៀង លើអ្នកដំណើរជនជាតិវៀតណាម ចំនួន ០២នាក់ |

| | | |
|---|---|---|
| មីនា ២០២១ | ថ្ងៃទី៣ | សេចក្តីជូនព័ត៌មានបន្ថែមរបស់ក្រសួងសុខាភិបាល ស្តីពី ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ដល់មន្ត្រីរាជការទទួលបន្ទុកប្រមូលចំណូល ជាពិសេសមន្ត្រីនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ |
| | ថ្ងៃទី២ | សម្តេចតេជោនាយករដ្ឋមន្ត្រីបានបង្ហោះខ្លឹមសារនៅលើគេហទំព័រហ្វេសប៊ុកផ្លូវការរបស់សម្តេច៖ វ៉ាក់សាំងកូវីដ១៩ ជំហានទី១ ពីមជ្ឈមណ្ឌលកូវ៉ាក់ ដែលជាជំនួយរបស់ WHO បានផ្តល់មកប្រទេសកម្ពុជា ចំនួន ៣២៤,០០០ដូស របស់ក្រុមហ៊ុន AstraZeneca ដែលផលិតនៅប្រទេសឥណ្ឌា បានដឹក និងប្រគល់ដល់ប្រទេសកម្ពុជាហើយកាលពីវេលាម៉ោង ៧:៥០នាទី យប់ថ្ងៃទី២ ខែមីនា ឆ្នាំ២០២១។ |
| | | សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី ព្រះរាជាណាចក្រកម្ពុជា ស្ថិតក្នុងចំណោមប្រទេសដំបូងគេដែលទទួលបានវ៉ាក់សាំងកូវីដ១៩ AstraZeneca/SII ពីយន្តការ COVAX |
| | | សេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលរាជធានីភ្នំពេញ ស្តីពី ការផ្អាកជាបណ្តោះអាសន្ននូវកិច្ចប្រជុំសាមញ្ញលើកទី២២ របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ |
| | | សេចក្តីណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្អាករៀបចំកិច្ចប្រជុំជាបណ្តោះអាសន្ន និងការបន្តអនុវត្តវិធានការបង្ការ និងទប់ស្កាត់ជំងឺកូវីដ១៩ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| | | សេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តបន្ទាយមានជ័យ ស្តីពី ករណីអ្នកជំងឺម្នាក់នៅខេត្តបន្ទាយមាន-ជ័យ បានទទួលមរណភាព ដោយជំងឺហើមសួត និងខ្សោយតម្រងនោមដំណាក់កាលចុងក្រោយ |
| | | សេចក្តីសម្រេចរបស់រដ្ឋបាលខេត្តព្រះសីហនុ ស្តីពី ការដាក់ សណ្ឋាគារ ភោជនីយដ្ឋាន អាគារស្នាក់នៅរួមផ្សារទំនើប មន្ទីរពេទ្យឯកជន ចំនួន ២៩ទីតាំង ស្ថិតនៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលរដ្ឋបាលខេត្តបានចេញលិខិតផ្អាកអាជីវកម្មជាបណ្តោះអាសន្ន ជាមណ្ឌលចត្តាឡីស័ក |
| | | សេចក្តីអំពាវនាវ (លើកទី៥) របស់រដ្ឋបាលខេត្តព្រះសីហនុ ដល់បងប្អូនប្រជាពលរដ្ឋ សាធារណជន អនុវត្តវិធានការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺរីករាលដាលនៃជំងឺកូវីដ១៩ ចូលទៅក្នុងសហគមន៍ |
| | | សេចក្តីសម្រេចរបស់រដ្ឋបាលខេត្តព្រះសីហនុ ស្តីពី ការដាក់សណ្ឋាគារ សាកាណា (SAKANA HOTEL) ជាកន្លែងព្យាបាលអ្នកជំងឺកូវីដ១៩ នៅខេត្តព្រះសីហនុ |
| | | សេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តព្រះសីហនុ ស្តីពី ការអញ្ជើញបងប្អូនដែលមានរោគសញ្ញាជំងឺកូវីដ១៩ និងធ្លាប់មានទំនាក់ទំនងជិតដិត ជាពិសេសម្ចាស់រថយន្តឈ្នួល និងម៉ូតូកង់បី ដែលទាក់ទងនឹងករណីស្ត្រីជនជាតិចិនម្នាក់ស្នាក់នៅសណ្ឋាគារយៀកឡាយ មកធ្វើតេស្តសំណាក |
| | | រដ្ឋបាលខេត្តព្រះសីហនុ ជម្រាបពីការផ្អាកជាបណ្តោះអាសន្ន និងដាក់ជាមណ្ឌលចត្តាឡីស័ក៖<br>- សណ្ឋាគារ សមុទ្រខៀវ (BLUE BAY) ផ្លូវ ២ធ្នូ ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ<br>- សណ្ឋាគារ អាលីយ៉ា អ៊ិនធើណេសិនណល ផ្លូវ ២៣តុលា ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ<br>- សណ្ឋាគារ 520 ហូថែល វិថីឆ្នេរអូរត្រេះ ភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ។ |
| | | ក្រសួងមហាផ្ទៃជម្រាបជូន អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត ស្តីពី ការផ្អាកការរៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១ របស់រដ្ឋបាលរាជធានី-ខេត្ត និងក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន។ |
| | ថ្ងៃទី១ | សេចក្តីជូនដំណឹងរបស់រដ្ឋបាលរាជធានីភ្នំពេញ ស្តីពី ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលជូនបងប្អូនប្រជាពលរដ្ឋ ដែលធ្វើចត្តាឡីស័កទាំងអស់នៅរាជធានីភ្នំពេញ ដែលស្របនឹងលក្ខខណ្ឌទាំងបួន៖ ១) អ្នកពាក់ព័ន្ធផ្ទាល់ជាមួយនឹងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ ២) អ្នកដែលបានទទួលការធ្វើតេស្ត ហើយលទ្ធផលអវិជ្ជមាន ៣) អ្នកដែលធ្វើចត្តាឡីស័កនៅតាមផ្ទះ និងសណ្ឋាគារ និង៤) អ្នកដែលមានជីវភាពខ្វះខាត |
| | | នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងបប្រកាសព័ត៌មាន ស្តីពី បុគ្គលវិជ្ជមានកូវីដ១៩ម្នាក់ ធ្លាប់បានចូលផ្សារម៉ាក្រូ ភ្នំពេញ វេលាម៉ោង ៥:៤១នាទី ដល់ម៉ោង ៦:៤៨នាទី ល្ងាចថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១។<br>១. អ្នកដែលមានរោគសញ្ញា និងធ្លាប់ចេញចូលទៅផ្សារម៉ាក្រូនៅថ្ងៃ និងពេលវេលាខាងលើ ត្រូវទៅធ្វើតេស្ត នៅទីតាំងដែលបានកំណត់ដោយអាជ្ញាធរសុខាភិបាល រាជធានី-ខេត្ត។<br>២. ចំពោះបុគ្គលមិនមានរោគសញ្ញា ត្រូវតាមដានសុខភាពចំនួន ១៤ថ្ងៃ រាប់ចាប់ពីថ្ងៃទី២០ ខែកុម្ភៈ ទៅ។ |

| | | |
|---|---|---|
| មីនា ២០២១ | ថ្ងៃទី១ | រដ្ឋលេខាធិការក្រសួងសុខាភិបាល អំពាវនាវដល់ប្រជាពលរដ្ឋ ពាក់ព័ន្ធព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ ដែលបានយកសំណាកលើកទី១ រួចរាល់ មុនថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ ទៅយកសំណាកលើកទី២ នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១ នៅទីតាំងចំនួនពីរ គឺនៅពហុកីឡាដ្ឋានជាតិអូឡាំពិក សម្រាប់ប្រជាពលរដ្ឋខ្មែរ និងនៅកោះពេជ្រ អាគារសហគមន៍សម្រាប់ជនជាតិចិន។ |
| | | សេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តកំពង់ចាម ស្តីពី លទ្ធផលអវិជ្ជមានកូវីដ១៩ របស់ជនជាតិចិន និងបងប្អូនកម្មករដែលកំពុងសាងសង់សំណង់នៅមជ្ឈមណ្ឌលពាណិជ្ជកម្មវឌ្ឍនៈ ក្រុងកំពង់ចាម ដែលមានការសង្ស័យចំនួន ៥៥នាក់ និងប្រជាពលរដ្ឋដែលជាប់ពាក់ព័ន្ធនឹងពិធីមង្គលការនៅភូមិកោះតូច ឃុំពាមជីកង ស្រុកកងមាស ចំនួន ២៩២នាក់ |
| | | មន្ទីរសុខាភិបាលខេត្តកណ្តាល បើកដំណើរការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ ជូនមន្ត្រីសុខាភិបាលជួរមុខ និងមន្ត្រីកងកម្លាំងនគរបាលខេត្តកណ្តាល។ |
| | | មន្ទីរសុខាភិបាលខេត្តស្ទឹងត្រែង បើកដំណើរការចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ ជូនមន្ត្រីសុខាភិបាល និងកម្លាំងនគរបាលជាតិខេត្តស្ទឹងត្រែង។ |
| | | សំណើរបស់មន្ទីរសុខាភិបាលខេត្តកំពត ដល់អភិបាលនៃគណៈអភិបាលខេត្តកំពត ស្តីពី ការបើកយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ១៩ ( Sinopharm Beijing Institute of Biological Products ) ជូនដល់មន្ត្រីសុខាភិបាល កងកម្លាំងប៉ូលីស និងអាជ្ញាធរជួរមុខ ដូចជាអភិបាលរងខេត្ត អភិបាល-អភិបាលរងស្រុក/ខណ្ឌ គណកម្ម-ការភូមិ-ឃុំ-សង្កាត់ នៃរដ្ឋបាលខេត្តកំពត |
| | | រដ្ឋបាលខេត្តព្រះសីហនុ ជម្រាបពី ការផ្អាកជាបណ្តោះអាសន្នសណ្ឋាគារ ភោជនីយដ្ឋាន ៨៨១១ ផ្លូវ៧០៧ ភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ។ |
| កុម្ភៈ ២០២១ | ថ្ងៃទី២៨ | សម្តេចតេជោនាយករដ្ឋមន្ត្រីបានបង្ហោះខ្លឹមសារនៅលើគេហទំព័រហ្វេសប៊ុកផ្លូវការរបស់សម្តេច៖ ប្រសិនបើពុំមានការប្រែប្រួល សម្តេចនឹងចាក់វ៉ាក់សាំងនៅម៉ោង ៨និង៣០នាទី ព្រឹកថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ នៅមន្ទីរពេទ្យកាល់ម៉ែត្រ។ |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងសុខាភិបាល ស្តីពី កម្មវិធីចាក់វ៉ាក់សាំងកូវីដ១៩ ស៊ីណូហ្វាម ជូនបងប្អូនកម្មករប្រមូលសំរាមនៅរាជធានីភ្នំពេញ |
| | | សេចក្តីប្រកាសព័ត៌មានរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពី លទ្ធផលនៃសម័យប្រជុំគណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី ថ្ងៃអាទិត្យ ទី២៨ ខែកុម្ភៈ ឆ្នាំ២០២១៖<br>១. សេចក្តីព្រាងច្បាប់ ស្តីពី វិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត<br>២. បញ្ហាផ្សេងៗ៖<br>- រាជរដ្ឋាភិបាល សម្រេចរៀបចំកម្មវិធីចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ ជូនដល់កម្មករប្រមូលសំរាម អ្នករត់តាក់ស៊ី អ្នករត់តាក់ស៊ី អ្នកបើកម៉ូតូកង់បី អ្នករត់ម៉ូតូឌុប នៅពេលខាងមុខនេះ។<br>- រាជរដ្ឋាភិបាល សម្រេចប្រគល់ភារកិច្ចជូន រដ្ឋមន្ត្រីក្រសួងសុខាភិបាល ជាតំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទៅទទួលយកវ៉ាក់សាំងការពារជំងឺកូវីដ១៩ ដែលជាអំណោយរបស់អង្គការសុខភាពពិភពលោក ដែលនឹងមកដល់កម្ពុជាក្នុងពេលឆាប់ៗខាងមុខនេះ។ |
| | | សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី ការមកដល់នូវវ៉ាក់សាំងអាស្ត្រាហ្សេនីកា ចំនួន ៣២៤.០០០ដូស នៅថ្ងៃទី២ ខែមីនា ឆ្នាំ២០២១ ដែលជាចំនួនវ៉ាក់សាំងជាជំនួយលើកដំបូង ផ្តល់ដោយមជ្ឈមណ្ឌលកូវ៉ាក់ |
| | | សេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តត្បូងឃ្មុំ ជម្រាបពី ការចូលរួមរបស់បុរសម្នាក់ដែលមានវិជ្ជមានជំងឺកូវីដ១៩ ក្នុងកម្មវិធីឡើងគេហដ្ឋាន និងចំណាត់ការមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត ឱ្យដឹកនាំចុះស្រាវជ្រាវ និងកំណត់មុខសញ្ញាដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍នេះ។ |

| | | |
|---|---|---|
| កុម្ភៈ ២០២១ | ថ្ងៃទី២៨ | រដ្ឋបាលខេត្តព្រះសីហនុ ជម្រាបពីការផ្អាកជាបណ្តោះអាសន្នៈ<br>- សណ្ឋាគារ អ៊ីស្តុន ហ្គ្រេនហូថែល វិថីពូឡូវ៉េ (៣០០) ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ<br>- អាគារស្នាក់នៅរួម «៧៨» ផ្លូវ១២៥ ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ<br>- អាគារស្នាក់នៅរួម «PAMA» ផ្លូវ១០២ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ<br>- អាគារស្នាក់នៅរួម «១០០» ផ្លូវ១២៤ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ<br>- អាគារស្នាក់នៅរួម «សម្បត្តិ» ផ្លូវ១២៤ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ<br>- សណ្ឋាគារ សានសាងចុងគ័រ ផ្លូវ១២៤ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ<br>- សណ្ឋាគារ មីងម៉ិនអន្តរជាតិ វិថីឯករាជ្យ (ផ្លូវ១០០) ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ<br>- សណ្ឋាគារ ស៊ីហ៊ូ អ៊ិនធើណេសិនណល វិថី២ធ្នូ ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ។ |
| | ថ្ងៃទី២៧ | សេចក្តីជូនដំណឹងរបស់ក្រសួងសុខាភិបាល ស្តីពី កម្មវិធីចាក់វ៉ាក់សាំងកូវីដ១៩ ជាបន្ត ចាប់ពីថ្ងៃចន្ទ ទី១ ខែមីនា ឆ្នាំ២០២១ |
| | | សេចក្តីជូនដំណឹងរបស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន ស្តីពី ការដាក់កម្ពុជាក្នុងបញ្ជីប្រទេសដែលមានជំងឺកូវីដ១៩ ទម្រង់ថ្មី ដោយរដ្ឋាភិបាលជប៉ុន |
| | ថ្ងៃទី២៦ | ទីស្តីការគណៈរដ្ឋមន្ត្រី គោរពជូន ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋមន្ត្រីប្រតិភូ គ្រប់ក្រសួងស្ថាប័ន ស្តីពី ករណីលើកសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃសុក្រ ទី៥ ខែមីនា ឆ្នាំ២០២១ |
| | | ក្រសួងទេសចរណ៍ ជម្រាបជូន អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត ស្តីពី ការផ្អាកដំណើរការអាជីវកម្មក្លឹបហាត់ប្រាណដើម្បីសុខភាព នៅក្នុង និងនៅក្រៅសណ្ឋាគារ នៅទូទាំងរាជធានី-ខេត្ត ឡើងវិញជាបណ្តោះអាសន្ន។ |
| | | អភិបាលរាជធានីភ្នំពេញ បានបញ្ជាក់ឱ្យដឹងថា រហូតមកដល់ពេលនេះ នៅរាជធានីភ្នំពេញ មិនមានការបិទភូមិ-សង្កាត់ណាមួយ ក្នុងខណ្ឌទាំង១៤ ដោយសារការឆ្លងជំងឺកូវីដ១៩ ចូលសហគមន៍ឡើយ។ |
| | | រដ្ឋលេខាធិការក្រសួងសុខាភិបាល បានឱ្យដឹងថា ការពាក់ម៉ាសគឺអាចការពារការចម្លងវីរុសបានតែតាមរយៈមាត់ និងច្រមុះតែប៉ុណ្ណោះ ខណៈដែលភ្នែក និងត្រចៀក ក៏ជាកន្លែងសំខាន់ដែលវីរុស អាចចម្លងទៅក្នុងខ្លួនបុគ្គលគ្រប់រូបផងដែរ ដូច្នេះដើម្បីការពារចំណុចនេះ អ្វីដែលសំខាន់បំផុតគឺ ការលាងដៃជាមួយនឹងសាប៊ូដែល និងអាល់កុលជាដើម។ |
| | | ក្រសួងមហាផ្ទៃ ជម្រាបជូនពីការអនុវត្តវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ។ |
| | | សេចក្តីសម្រេចរបស់ក្រសួងសុខាភិបាល ស្តីពី ការបង្កើតអនុគណៈកម្មការគ្រប់គ្រងសន្តិសុខ និងសណ្តាប់ធ្នាប់នៅតាមគោលដៅ និងតំបន់ចត្តាឡីស័កដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ |
| | | សេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តកំពង់ចាម ជម្រាបពី ការចូលរួមរបស់បុរសដែលមានវិជ្ជមានជំងឺកូវីដ១៩ ម្នាក់ ក្នុងពិធីអាពាហ៍ពិពាហ៍នៅខេត្តកំពង់ចាម និងចំណាត់ការមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តឱ្យដឹកនាំមន្ត្រីចុះស្រាវជ្រាវ និងកំណត់មុខសញ្ញាដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍នេះ។ |
| | | រដ្ឋបាលខេត្តព្រះសីហនុ ជម្រាបពីការផ្អាកជាបណ្តោះអាសន្ន សណ្ឋាគារ អេស អេស ហូថេល & រេស៊ីដិន ស្ថិតនៅផ្លូវលេខ១២៨ ភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ |
| | | រដ្ឋបាលខេត្តព្រះសីហនុ ជម្រាបពីការផ្អាកជាបណ្តោះអាសន្ន មន្ទីរពេទ្យឯកជន ថៃខាង ស្ថិតនៅផ្លូវឯករាជ្យ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ |
| | | រដ្ឋបាលខេត្តព្រះសីហនុ ជម្រាបពីការផ្អាកជាបណ្តោះអាសន្ន សណ្ឋាគារ កាស៊ីណូ ហ្វូដជេស អេន លីប៊ើធី ស្ថិតនៅភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ |
| | | សេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលខេត្តបន្ទាយមានជ័យ ស្តីពី ករណីស្លាប់ពលករជាអ្នកជំងឺបានត្រឡប់ពីប្រទេសថៃ ដែលទទួលមរណភាពដោយមូលហេតុជំងឺរលាកស្រោមខួរ និងជំងឺបេងសួត និងបញ្ជាក់ផងដែរថាមិនមែនជាករណីស្លាប់ដោយសារជំងឺកូវីដ១៩ នោះទេ |

| | | |
|---|---|---|
| ខែកុម្ភៈ ២០២១ | ថ្ងៃទី២៦ | សេចក្ដីណែនាំបន្ថែមរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្ដីពី វិធានការបន្ទាន់ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការរាតត្បាតជំងឺកូវីដ១៩ ក្នុងសហគមន៍ពាក់ព័ន្ធនឹងព្រឹត្តិកាណ៍សហគមន៍ ២០កុម្ភៈ |
| | ថ្ងៃទី២៥ | សេចក្ដីជូនដំណឹងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្ដីពី លទ្ធផលនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងកូវីដ១៩ សម្រាប់ជុំទី៤ លើកទី១។ គិតត្រឹមថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ ចំនួនសរុបនៃគ្រួសារដែលទទួលបានសេវាឧបត្ថម្ភមានចំនួន ៦៨៨.៥៣៩គ្រួសារ និងចំនួនទឹកប្រាក់សរុប ១២២.១៥៦.២០៨.០០០រៀល។ |
| | | ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ជម្រាបជូនសម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ ស្ដីពី ករណីសុំគោលការណ៍អនុវត្តច្បាប់ ចំពោះបុគ្គលមិនអនុវត្តតាមវិធានរបស់សុខាភិបាល ចំពោះការធ្វើចត្តាឡីស័ក បុគ្គលគេចវេសមិនព្រមចូលព្យាបាល ឬមិនសហការផ្ដល់ការសម្ភាស និងទីតាំងដែលមិនសហការផ្ដល់ព័ត៌មានការស្រាវជ្រាវ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ បន្ថែមលើអនុក្រឹត្យលេខ២២៧ អនក្រ.បក។ |
| | | រដ្ឋបាលខេត្តកណ្ដាលជម្រាបមក អភិបាល នៃគណៈអភិបាលក្រុងតាខ្មៅ និងអភិបាល នៃគណៈអភិបាលស្រុក គ្រប់ស្រុក ស្ដីពី ការពន្យារពេល ឬកាត់បន្ថយអ្នកចូលរួមឱ្យមានចំនួនតិច ចំពោះការរៀបចំពិធីមង្គលការ ឬការរៀបចំពិធីផ្សេងៗ ក្នុងភូមិសាស្ត្រខេត្តកណ្ដាល។ |
| | | ក្រសួងមហាផ្ទៃជម្រាបមក អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត ស្ដីពី ការផ្អាកការប្រារព្ធពិធីសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ និងការអនុវត្តកិច្ចការបន្តរបស់រដ្ឋបាលរាជធានី-ខេត្ត។ |
| | | សេចក្ដីជូនដំណឹងរបស់គណៈដឹកនាំជាន់ខ្ពស់នៃសាសនាឥស្លាមកម្ពុជា ស្ដីពី ការផ្អាកជួបជុំសឡាតជុំអាត់ថ្ងៃសុក្រ និងសឡាតពើរដើម៉ាអះ នៅគ្រប់ម៉ាស្ជិទ និងស៊ូរ៉ាវ សម្រាប់រាជធានីភ្នំពេញ ខេត្តកណ្ដាល និងខេត្តព្រះសីហនុ គិតចាប់ពីថ្ងៃសុក្រ ទី២៦ ខែកុម្ភៈ រហូតដល់ថ្ងៃសៅរ៍ ទី១៣ ខែមីនា ឆ្នាំ២០២១ |
| | | សេចក្ដីអំពាវនាវរបស់រដ្ឋបាលខេត្តព្រះសីហនុ ស្ដីពី លទ្ធផលធ្វើតេស្តសំណាកលើជនបរទេសដែលស្នាក់នៅខេត្តព្រះសីហនុមានវិជ្ជមានជំងឺកូវីដ១៩ កើនឡើងចំនួន ០៨នាក់ |
| | | រដ្ឋបាលខេត្តព្រះសីហនុ ជម្រាបពីការផ្អាកជាបណ្ដោះអាសន្ន អាគារស្នាក់នៅរួម វីន ក្យូឈ័រ ខុនដូ- អាជីវកម្ម ស្ថិតនៅផ្លូវលេខ២១០ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ |
| | | ក្រសួងសាធារណការ និងដឹកជញ្ជូន សូមគោរពជូនសម្ដេចតេជោនាយករដ្ឋមន្ត្រី ស្ដីពី សំណើសុំលុបចោលនូវការជ្រើសរើសមន្ត្រីក្របខណ្ឌថ្មីចំនួន ១៣៣កន្លែង របស់ក្រសួងសាធារណការ និងដឹកជញ្ជូនសម្រាប់ឆ្នាំ២០២១ ក្នុងគោលបំណងរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធនឹងការរីករាលដាលនៃជំងឺកូវីដ១៩ និងដើម្បីចូលរួមសន្សំសំចៃថវិកាជាតិសម្រាប់ទ្រទ្រង់ស្ថិរភាពសេដ្ឋកិច្ច និងសង្គមក្នុងគ្រាលំបាកនេះ |
| | ថ្ងៃទី២៤ | ប្រកាសរបស់ក្រសួងមហាផ្ទៃ ស្ដីពី ការបណ្ដេញជនបរទេសឈ្មោះ Shen Kaidong ( នាយកសារព័ត៌មាន Angkor Today ) ចេញពីព្រះរាជាណាចក្រកម្ពុជា ពាក់ព័ន្ធបទល្មើសប្រព្រឹត្តនៅព្រះរាជាណាចក្រកម្ពុជា ទៅប្រទេសដើមវិញ និងហាមឃាត់ចូលព្រះរាជាណាចក្រកម្ពុជាជាថ្មី |
| | | ប្រកាសរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន ស្ដីពី ការលុបប្រកាសរបស់ក្រសួងព័ត៌មាន ដែលបានអនុញ្ញាតឱ្យលោក អ៊ុង គង្គា បើកដំណើរការធ្វើអាជីវកម្មកាសែតអង្គរធូដេ ( Angkor Today ) ដោយម្ចាស់អាជ្ញាបណ្ណបានផ្សព្វផ្សាយព័ត៌មានបំភ្លៃការពិតមានចេតនាទុច្ចរិតធ្វើឱ្យអន្តរាយដល់សុខភាពសាធារណៈ បង្កភាពច្របូកច្របល់ ចលាចលនៅក្នុងសង្គមដែលអាចប៉ះពាល់ដល់សន្តិសុខជាតិ និងដល់កិត្យានុភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលជាការបំពានយ៉ាងធ្ងន់ធ្ងរលើវិជ្ជាជីវៈ និងកិច្ចសន្យាដែលសាមីខ្លួនបានតម្កល់ទុកនៅក្រសួងព័ត៌មាន |

| | | |
|---|---|---|
| កុម្ភៈ ២០២១ | | សេចក្តីណែនាំបន្ថែមរបស់ក្រសួងពាណិជ្ជកម្ម ស្តីពី វិធានការការពារ និងទប់ស្កាត់ការរាតត្បាតជំងឺកូវីដ១៩ ក្នុងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ |
| | | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ប្រកាសចាក់វ៉ាក់សាំងកូវីដ១៩ ដោយឥតគិតថ្លៃ ដល់ជនបរទេសទាំងអស់ដែលកំពុងធ្វើការ និងស្នាក់នៅក្នុងប្រទេសកម្ពុជា តាមរយៈកម្មវិធីចាក់វ៉ាក់សាំងកូវីដ១៩របស់កម្ពុជា។ |
| | | សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ប្រទេសកម្ពុជា ស៊ុយអែត និងយូនីសេហ្វរួមគ្នាការពារការអប់រំសម្រាប់កុមារដែលសាលារៀនខ្លួនត្រូវបានប្រើប្រាស់ជាមជ្ឈមណ្ឌលចត្តាឡីស័ក |
| | | សេចក្តីជូនដំណឹងរបស់សាលាឧទ្ធរណ៍ភ្នំពេញ ស្តីពី ការលើកពេលសវនាការដែលបានគ្រោងទុកចាប់ពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ទៅពេលក្រោយវិញ |
| | | រដ្ឋបាលរាជធានីភ្នំពេញចេញផ្សាញទីតាំងពាក់ព័ន្ធព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការផ្អាកដំណើរការសិក្សានៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាបណ្តោះអាសន្នរយៈពេល ០២សប្តាហ៍ នៅក្រុងព្រះសីហនុ និងស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ |
| | ថ្ងៃទី២៤ | សេចក្តីជូនដំណឹងរបស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ អនុគណៈកម្មការស្រាវជ្រាវ និងតាមដានបុគ្គលសង្ស័យថាមានផ្ទុកជំងឺកូវីដ១៩ ស្តីពី ការបន្ថែមប្រព័ន្ធលេខទូរស័ព្ទ CELLCARD ចំនួន ១២ខ្សែ បន្ថែមលើលេខទូរស័ព្ទចំនួន ២៤ខ្សែ ដែលបានជូនដំណឹងកន្លងមក សម្រាប់ទំនាក់ទំនងសម្ភាសន៍ និងប្រមូលព័ត៌មាន |
| | | សេចក្តីជូនណែនាំរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ស្តីពី វិធានការបន្ទាន់សម្រាប់ការបង្ការ និងទប់ស្កាត់ការរីករាតត្បាតជំងឺកូវីដ១៩ ពាក់ព័ន្ធនឹងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ |
| | | ក្រសួងអប់រំ យុវជន និងកីឡា ជម្រាបជូនអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ ស្តីពី សំណើផ្អាកដំណើរការអាជីវកម្មក្លឹបហាត់ប្រាណ និងផ្អាកការលេងកីឡា ឬការហាត់ប្រាណគ្រប់ប្រភេទ ដែលមានលក្ខណៈប្រមូលផ្តុំជាបណ្តោះអាសន្ននៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងក្រុងព្រះសីហនុ នៃខេត្តព្រះសីហនុ |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងទេសចរណ៍ ស្តីពី ការផ្អាកដំណើរការជាបណ្តោះអាសន្ន នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃ ក្រោមឱវាទក្រសួងទេសចរណ៍ នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល រយៈពេល ០២សប្តាហ៍ |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ស្តីពី ការបិទដំណើរការបណ្តោះអាសន្នរយៈពេល ០២សប្តាហ៍ រោងភាពយន្ត រោងសម្តែងសិល្បៈ និងសារមន្ទីរ នៅក្នុងខេត្តព្រះសីហនុ |
| | | សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី វិធានការសម្រាប់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ក្នុងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ |
| | ថ្ងៃទី២៣ | សេចក្តីប្រកាសព័ត៌មានរបស់គណៈកម្មាធិការជាតិ អូឡាំពិកកម្ពុជា ស្តីពី ការផ្អាកទិវារត់ប្រណាំងកម្សាន្តស្ត្រី និងកីឡាដែលគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា និងក្រសួងទេសចរណ៍ គ្រោងរៀបចំក្នុងទិវានារីអន្តរជាតិ ៨ មីនា ឆ្នាំ២០២១ |
| | | សេចក្តីជូនដំណឹងរបស់គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ អនុគណៈកម្មការស្រាវជ្រាវ និងតាមដានបុគ្គលសង្ស័យថាមានផ្ទុកជំងឺកូវីដ១៩ ស្តីពីការប្រើប្រាស់លេខទូរស័ព្ទចំនួន ២៤ខ្សែ មានប្រព័ន្ធ SMART ចំនួន ១២ខ្សែ និងប្រព័ន្ធ METFONE ចំនួន ១២ខ្សែ សម្រាប់ទំនាក់ទំនងសម្ភាសន៍ និងប្រមូលព័ត៌មាន |
| | | ធនាគារជាតិនៃកម្ពុជា ជម្រាបមកលោក លោកស្រី អគ្គនាយក អគ្គនាយិកា នាយក នាយិកា គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ស្តីពីការពង្រឹងការអនុវត្តវិធានការដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ក្នុងបរិបទនៃព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ |

| | | |
|---|---|---|
| កុម្ភៈ ២០២១ | ថ្ងៃទី២៣ | សេចក្តីជូនដំណឹងរបស់ធនាគារជាតិនៃកម្ពុជា ស្តីពី ការលើកពេលប្រឡងជ្រើសរើសនិស្សិតចូលរៀនថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់ បច្ចេកទេសធនាគារជំនាន់ទី៣០ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២១ |
| | | សេចក្តីជូនដំណឹងរបស់អង្គភាពប្រឆាំងអំពើពុករលួយ ស្តីពី ការលើកពេល នៃដំណើរការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌមន្ត្រីរាជការស៊ីវិល នៃអង្គភាពប្រឆាំងអំពើពុករលួយ សម័យប្រឡង ២៧ កុម្ភៈ ២០២១ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| | | សេចក្តីជូនដំណឹងរបស់បណ្ឌិត្យសភានគរបាលកម្ពុជា ក្រសួងមហាផ្ទៃ ស្តីពី ការផ្អាកការប្រឡងប្រជែងជ្រើសរើសនិស្សិតអាហារូបករណ៍ឱ្យចូលសិក្សាថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រនគរបាល សិក្សារយៈពេល ៤ ឆ្នាំ សម្រាប់ឆ្នាំ២០២០ នៅបណ្ឌិត្យសភានគរបាលកម្ពុជា |
| | | សេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ស្តីពី ការផ្អាកសន្និសីទសារព័ត៌មានរយៈពេល ០២សប្តាហ៍ |
| | | សេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្តកំពង់ស្ពឺ បញ្ជាក់ជូនថាមិនមានករណីឆ្លងជំងឺកូវីដ១៩ ដូចការផ្សាយនៅតាមបណ្តាញសង្គមនោះទេ |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការផ្អាកការពិនិត្យកាយសម្បទាដោយផ្ទាល់នៅនាយកដ្ឋានពេទ្យការងារ |
| | | សេចក្តីណែនាំរបស់ក្រសួងទេសចរណ៍ ស្តីពី ការអនុវត្តវិធានសុវត្ថិភាពសម្រាប់មន្ត្រីរាជការ និងភ្ញៀវជាតិអន្តរជាតិ នៅបរិវេណទីស្តីការក្រសួងទេសចរណ៍ និងក្នុងការិយាល័យធ្វើការ |
| | | សេចក្តីជូនដំណឹងរបស់សាលាដំបូងរាជធានីភ្នំពេញ ស្តីពី ការលើកពេលសវនាការ ដែលបានគ្រោងទុកនៅចន្លោះពេលពី ថ្ងៃទី២៤ ខែកុម្ភៈ ដល់ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ទៅពេលក្រោយវិញ។ ពាក់ព័ន្ធនឹងសំណុំរឿងចាំបាច់មួយចំនួន លោក លោកស្រីចៅក្រមពិនិត្យ និងចាត់ការតាមការជាក់ស្តែង យោងតាមករណីនីមួយៗ ដោយគោរពតាមវិធានការណែនាំរបស់ក្រសួងសុខាភិបាល និងកាត់បន្ថយការប្រមូលផ្តុំ។ |
| | | រដ្ឋបាលខេត្តព្រះសីហនុ ជម្រាបពីការផ្អាកអាជីវកម្មបណ្តោះអាសន្ន សណ្ឋាគារជីនប៊ី ទាំង ៣សាខា និងបិទអាគារស្នាក់នៅរួមរបស់បុគ្គលិកក្រុមហ៊ុនជីនប៊ី នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។ |
| | | សេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្តព្រះសីហនុ ឱ្យបានជ្រាបថា កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ កន្លងទៅ ក្រុមឆ្លើយតបបន្ទាន់នៃមន្ទីរសុខាភិបាលខេត្តបានយកសំណាកតេស្តពីជនបរទេសដែលស្នាក់នៅក្នុងក្រុងព្រះសីហនុ ហើយលទ្ធផលតេស្តបានបញ្ជាក់ថាមានវិជ្ជមានវីរុសកូវីដ១៩ ចំនួន ០២នាក់។ |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ស្តីពី ការបិទដំណើរការជាបណ្តោះអាសន្នរយៈពេល ០២ សប្តាហ៍ រោងភាពយន្ត រោងសម្តែងសិល្បៈ និងសារមន្ទីរ នៅក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល |
| | | សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី ករណីវិជ្ជមានជំងឺកូវីដ១៩ ថ្មីចំនួន ២៥នាក់ និងមិនមានករណីជាសះស្បើយ ព្រមទាំងមានការរកឃើញវីរុសកូរ៉ូណាបំប្លែងថ្មីលើអ្នកជំងឺ ០៣នាក់ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ |
| | ថ្ងៃទី២២ | សេចក្តីណែនាំរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ក្រោមឱវាទក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្តីពីការចូលរួមអនុវត្តឱ្យមានប្រសិទ្ធិភាពខ្ពស់តាមវិធានការសុខភាពទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ១៩ |
| | | សេចក្តីណែនាំរបស់រដ្ឋបាលរាជធានីភ្នំពេញ ស្តីពី ការរឹតបន្តឹងការអនុវត្តវិធានការគម្លាតសុវត្ថិភាពសង្គម និងគម្លាតសុវត្ថិភាពបុគ្គល នៅក្នុងមូលដ្ឋានរាជធានីភ្នំពេញ |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការផ្អាកដំណើរការសិក្សានៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាបណ្តោះអាសន្នរយៈពេល ០២សប្តាហ៍ នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល |
| | | សេចក្តីណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ក្នុងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ ២០២១ |

<table>
<tr><td rowspan="7">ឆ្នាំ: ២០២១</td><td rowspan="5">ថ្ងៃទី២២</td><td>សេចក្តីជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ការផ្អាកដំណើរការគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ជាបណ្តោះអាសន្នរយៈពេល ០២សប្តាហ៍ នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល</td></tr>
<tr><td>គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ អនុគណៈកម្មការស្រាវជ្រាវ និងតាមដានបុគ្គលសង្ស័យថាមានផ្ទុកជំងឺកូវីដ១៩ សូមគោរពជូនសម្តេចតេជោនាយករដ្ឋមន្ត្រី ស្តីពីសំណើសុំគោលការណ៍អនុវត្តច្បាប់ចំពោះបុគ្គលមិនអនុវត្តតាមវិធានរបស់សុខាភិបាលចំពោះការធ្វើចត្តាឡីស័ក បុគ្គលគេចវេសមិនព្រមចូលព្យាបាល ឬមិនសហការផ្តល់ការសម្ភាស និងទីតាំងដែលមិនសហការផ្តល់ព័ត៌មានការស្រាវជ្រាវ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ បន្ថែមលើអនុក្រឹត្យលេខ ២៧ អនក្រ.បក៖<br>១. ចំពោះជនបរទេស សូមគោរពស្នើសុំ បណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា និងហាមចូលប្រទេសសារជាថ្មី។<br>២. ចំពោះជនជាតិខ្មែរ សូមគោរពស្នើសុំចាត់វិធានការតាមផ្លូវច្បាប់។<br>៣. ចំពោះទីតាំង សូមដកហូតអាជ្ញាប័ណ្ណ និងបិទអាជីវកម្មក្នុងទីតាំង។</td></tr>
<tr><td>សារសំឡេងសម្តេចតេជោនាយករដ្ឋមន្ត្រី ស្តីពី ស្ថានភាពនៃជំងឺកូវីដ១៩ និងវិធានការបន្ទាន់៖<br>- ដោយមានការស្នើសុំពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា សូមផ្អាកដំណើរការសាលារៀនជាបណ្តោះអាសន្នរយៈពេល ០២សប្តាហ៍ យ៉ាងតិច នៅរាជធានីភ្នំពេញ និងខេត្តកណ្តាល។<br>- អំពាវនាវដល់បងប្អូនដែលត្រូវរៀបអាពាហ៍ពិពាហ៍ ប្រសិនបើអាចពន្យារពេលបាន សូមពន្យារពេលសិន។ ប្រសិនបើមិនអាច សូមមេត្តាកាត់បន្ថយចំនួនមនុស្សតាមដែលអាចធ្វើទៅបាន។<br>- អំពាវនាវដល់ប្រជាពលរដ្ឋដែលមានការពាក់ព័ន្ធ អ្នករត់តាក់ស៊ី អ្នករត់ម៉ូតូឌុប កង់បី Passapp សូមសហការ យកសំណាក និងធ្វើចត្តាឡីស័ក។<br>- អំពាវនាវដល់ប្រជាពលរដ្ឋនៅទីក្រុងភ្នំពេញ និងខេត្តកណ្តាល ប្រសិនបើមិនមានការចាំបាច់ សូមមេត្តាកុំចេញក្រៅ ដើម្បីចៀសវាងការឆ្លងរីករាលដាលដែលមើលមិនឃើញ។<br>- ព្រឹត្តិការណ៍ ២០កុម្ភៈ គឺមានភាពលំបាកជាងព្រឹត្តិការណ៍ ៣វិច្ឆិកា និងព្រឹត្តិការណ៍ ២៨វិច្ឆិកា។<br>- នៅតាមស្ថាប័ន សម្រាប់ការប្រជុំនានា បើអាចសូមពន្យារ បើមិនអាច សុំធ្វើការប្រជុំអនឡាញ។<br>- មិនបិទសកម្មភាពសេដ្ឋកិច្ចនោះទេ ដូចជារោងចក្រ សហគ្រាស ភោជនីយដ្ឋាន អាហារដ្ឋាន ប៉ុន្តែក៏សូមឱ្យមាននូវការយកចិត្តទុកដាក់ក្សោគម្លាតសុវត្ថិភាពឱ្យបានហ្មត់ចត់។<br>- បន្តប្រគល់អំណាចដល់អភិបាលរាជធានី-ខេត្ត ធ្វើការបិទចំពោះភោជនីយដ្ឋាន អាហារដ្ឋាន ឬកន្លែងលក់ដូរណាដែលមិនគោរពទៅតាមវិធានសុខាភិបាល។<br>- សូមឱ្យអភិបាលរាជធានីភ្នំពេញបន្តការចែកម៉ាសឱ្យប្រជាពលរដ្ឋក្រីក្រ អ្នកនៅតាមផ្សារ និងកន្លែងលក់ដូរ និងទីកន្លែងការងារមួយចំនួនទៀតដែលខ្វះម៉ាស ឯអ្នកដែលមានម៉ាស ពេលធ្វើដំណើរតាមផ្លូវចាំបាច់ត្រូវពាក់ម៉ាស។<br>- សូមគិតពីសុវត្ថិភាពសុខភាពផ្ទាល់ខ្លួន ដោយចាប់ផ្តើមពីមនុស្សម្នាក់ៗ។<br>- អំពាវនាវប្រជាពលរដ្ឋនៅតាមបណ្តាខេត្ត ប្រសិនបើអាចពន្យារពេលបានក្នុងការធ្វើដំណើរមកកាន់រាជធានីភ្នំពេញ សុំពន្យារពេលសិន។</td></tr>
<tr><td>សេចក្តីជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ការរឹតបន្តឹងការអនុវត្តវិធានការសុវត្ថិភាពសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនទូទាំងប្រទេស</td></tr>
<tr><td>សេចក្តីទូលថ្វាយ ប្រគេន និងជូនដំណឹងរបស់គណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ស្តីពី វិធានការបង្ការ និងទប់ស្កាត់ការរីករាលដាល នៃជំងឺកូវីដ១៩</td></tr>
<tr><td rowspan="2">ថ្ងៃទី២១</td><td>សេចក្តីជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការផ្អាកដំណើរការជាបណ្តោះអាសន្ន វិទ្យាល័យសម្តេច ហ៊ុន សែន ភ្នំពេញថ្មី និងសាលាអន្តរជាតិ អេស អាយ អេស សាខាឡាក់គីស្ទារ</td></tr>
<tr><td>ក្រសួងទេសចរណ៍ជម្រាបជូន អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ស្តីពី ការបន្តពង្រឹងវិធានការបិទផ្អាកអាជីវកម្ម KTV ក្លឹបកម្សាន្ត ( ខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀហ្គាឌិន ) និងការត្រួតពិនិត្យឱ្យបានម៉ឺងម៉ាត់ជាប់ជាប្រចាំ</td></tr>
</table>

| | | |
|---|---|---|
| ខែកុម្ភៈ ២០២១ | ថ្ងៃទី២១ | សេចក្តីជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការផ្អាកដំណើរការជាបណ្តោះអាសន្ន អនុវិទ្យាល័យឫស្សីជ្រោយ សាលាបឋមសិក្សា ហ៊ុន សែន ឫស្សីជ្រោយ ស្រុកស្អាង អនុវិទ្យាល័យឫស្សីស្រុក ស្រុកកៀនស្វាយ ខេត្តកណ្តាល សាលាបឋមសិក្សាកូលាបទី១ និងសាលារៀនអន្តរទ្វីបអាមេរិកាំង សាខាចាក់អង្រែ រាជធានីភ្នំពេញ |
| | | សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី កម្មវិធីចាក់វ៉ាក់សាំងកូវីដ១៩ ជាបន្ត ចាប់ពីថ្ងៃចន្ទ ទី២២ ខែកុម្ភៈ ឆ្នាំ២០២១ |
| | | ក្រសួងទេសចរណ៍ជម្រាបជូនអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត និងជាប្រធានគណៈកម្មការអភិវឌ្ឍន៍ទេសចរណ៍ថ្នាក់រាជធានី-ខេត្ត ស្តីពី ការបន្តជំរុញការអនុវត្តគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល និងវិធានសុវត្ថិភាពទេសចរណ៍នៅតាមមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ក្នុងរាជធានី-ខេត្ត។ |
| | ថ្ងៃទី២០ | សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី ការអនុវត្តប្រព័ន្ធបច្ចេកវិទ្យា QR Code "ទប់ស្កាត់កូវីដ១៩ (Stop Covid-19)" |
| | | សេចក្តីណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី វិធានការបង្ការជំងឺកូវីដ១៩ នៅតាមរោងចក្រ សហគ្រាស ក្នុងព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ការរឹតបន្តឹងការអនុវត្តវិធានការសុវត្ថិភាពសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន នៅរាជធានីភ្នំពេញ |
| | | សារពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី នាព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១៖<br>- ស្នើសុំការយោគយល់ពីអ្នកធុរកិច្ច និងការស្នាក់ការនៅរបស់ពលរដ្ឋ ដែលតម្រូវឱ្យមានការបិទអគារក្លឹបកម្សាន្ត N8 និងតំបន់មួយចំនួនដែលផ្ទុះករណីកូវីដ១៩ ជាចាំបាច់ ដោយមិនអនុញ្ញាតឱ្យចេញ-ចូល លើកលែងតែអ្នកដែលជាម្ចាស់ផ្ទះក្នុងតំបន់នោះ គឺឱ្យចូល តែមិនអនុញ្ញាតឱ្យចេញ។<br>- បន្តយកសំណាកធ្វើតេស្តសម្រាប់អ្នកនៅក្នុងតំបន់មានផ្ទុះកូវីដ១៩ ហើយបន្ទាប់ពីធ្វើតេស្តហើយត្រូវធ្វើចត្តាឡីស័ក ១៤ថ្ងៃ ដែលចំនួននៃការធ្វើតេស្តអាចនឹងមានចំនួនច្រើន។<br>- អាជ្ញាធរត្រូវបន្តស្វែងរកអ្នកពាក់ព័ន្ធនឹងក្លឹប N8 ដើម្បីស្វែងរកមកធ្វើតេស្ត និងធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ។<br>- ត្រូវធ្វើចត្តាឡីស័កសម្រាប់អ្នកដែលមានការពាក់ព័ន្ធទាំងអស់ និងត្រូវយកសំណាករបស់ពួកគាត់មកធ្វើតេស្តផងដែរ។<br>- អំពាវនាវដល់អ្នកពាក់ព័ន្ធនឹងក្លឹប N8 ទាំងអស់ និងពាក់ព័ន្ធនឹងអ្នកមានជំងឺកូវីដ១៩ ទាំង ៣២នាក់នេះ ម្ចាស់ការមកឱ្យពិនិត្យសំណាកជាចាំបាច់បំផុត។<br>- អំពាវនាវដល់ពលរដ្ឋនៅភ្នំពេញ និងតំបន់ដទៃទៀត បង្កើនការប្រុងប្រយ័ត្ន និងរឹតបន្តឹងការអនុវត្តវិធានការ ០៣ការពារ និង០៣កុំ ឱ្យបានជាប់លាប់ល្អតាមការណែនាំរបស់ក្រសួងសុខាភិបាល។<br>- មិនអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលទៅប្រទេសថៃ វៀតណាម និងឡាវ ទោះស្របច្បាប់ក៏ដោយ មិនស្របច្បាប់ក៏ដោយ ហើយសូមកងកម្លាំងការពារព្រំដែនបិទកុំឱ្យធ្វើដំណើរចេញ។ |
| | ថ្ងៃទី១៨ | អនុក្រឹត្យរាជរដ្ឋាភិបាលកម្ពុជាលេខ ២៧ អនក្រ.បក ស្តីពី វិធានការចត្តាឡីស័កដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ |
| | | អនុក្រឹត្យរាជរដ្ឋាភិបាលកម្ពុជាលេខ ២៨ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា៨ នៃអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពី វិធានការសុខាភិបាលដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល |
| | ថ្ងៃទី១៧ | សេចក្តីក្រើនរំលឹករបស់ក្រសួងសុខាភិបាល ស្តីពី កម្មវិធីចាក់វ៉ាក់សាំងកូវីដ១៩ ជាបន្ត នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ និងថ្ងៃបន្តបន្ទាប់ |
| | ថ្ងៃទី១៥ | សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការផាកពិន័យចំពោះបងប្អូនពលករកម្ពុជាដែលគេចវេសមិនបានធ្វើចត្តាឡីស័កត្រឹមត្រូវតាមវិធានការសុខាភិបាល |

| | | |
|---|---|---|
| ឆ្នាំ: ២០២១ | ថ្ងៃទី១៥ | សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី ការវិភាគមន្ទីរពិសោធន៍រកឃើញអ្នកមានជំងឺកូវីដ ១៩ បំប្លែងខ្លួនថ្មី លើអ្នកដំណើរជនជាតិបរទេសចំនួន ០៣នាក់ និងការណែនាំក្រើនរំឭកការអនុវត្តវិធានការការពារការចម្លងជំងឺកូវីដ១៩ នៅកម្ពុជា |
| | | ក្រសួងសុខាភិបាលជម្រាបជូន អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ស្តីពី ការក្រើនរំឭកការអនុវត្តអនុក្រឹត្យលេខ ១២៩ អនក្រ.បក ស្តីពី វិធានការសុខាភិបាលដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល |
| | | សារសំឡេងពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ជូនជនរួមជាតិទាក់ទងនឹង ការទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិ នៃជំងឺកូវីដ១៩ នៅតាមច្រកចេញចូលប្រទេសកម្ពុជា៖<br>- ដោយមានការឆ្លងរីករាលដាលក្នុងសហគមន៍ នៅភាគខាងជើងនៃប្រទេសវៀតណាម ភាគកណ្តាល រហូតមកដល់ភាគខាងត្បូង យើងក៏បានពង្រឹងនូវវិធានការថែមទៀតនៅព្រំដែនកម្ពុជា-វៀតណាម។<br>- ដោយឃើញថាពលរដ្ឋកម្ពុជាមួយចំនួនដែលធ្វើការនៅប្រទេសថៃ បានធ្វើដំណើរត្រឡប់មកកាន់កម្ពុជាវិញដោយឆ្លងកាត់តាមប្រទេសឡាវ ដូច្នេះយើងក៏បានពង្រឹងនូវការធ្វើចត្តាឡីស័ក និងត្រួតពិនិត្យនៅតាមព្រំដែនកម្ពុជា-ឡាវ រួមនិងកិច្ចសហប្រតិបត្តិការជាមួយប្រទេសឡាវ។<br>- ដាក់ចេញបទបញ្ជាអនុវត្តឱ្យបានត្រឹមត្រូវនូវអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពី វិធានការសុខាភិបាលដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល។<br>- សូមឱ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាលណែនាំទៅបណ្តាខេត្តអនុវត្តនូវជំពូកទី៥ ទាក់ទងនឹងទណ្ឌកម្ម នៅមាត្រា៨ សម្រាប់អ្នកគេចវេសធ្វើចត្តាឡីស័ក ឬមិនសហការជាមួយមន្ត្រីចត្តាឡីស័កក្នុងការអនុវត្តវិធានការសុខាភិបាល។<br>- ស្នើសុំរដ្ឋមន្ត្រីក្រសួងសុខាភិបាល សហការជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ធ្វើការកែតម្រូវមាត្រា៨ ឡើងវិញដោយបង្កើនចំនួនការពិន័យបន្ថែម និងរៀបចំអនុក្រឹត្យពង្រឹងការធ្វើចត្តាឡីស័កបន្ថែម។<br>- ចេញបញ្ជាឱ្យមន្ត្រីអនុវត្តច្បាប់ទាំងអស់ អនុវត្តឱ្យបានម៉ឺងម៉ាត់ចំពោះមេក្លោងនាំមនុស្សឆ្លងកាត់ព្រំដែនដោយពុំបានធ្វើចត្តាឡីស័ក និងអាចនាំដល់ការដកឋានន្តរស័ក្តិ ឬបណ្តេញចេញពីជួរនូវមន្ត្រីនគរបាលណាដែលអនុវត្តខុសឆ្គងទៅនឹងវិធានការទាំងឡាយ ដើម្បីប្រយុទ្ធនឹងការរត់ពន្ធមនុស្ស។<br>- ចេញបទបញ្ជាបណ្តាខេត្តតាមព្រំដែនកម្ពុជា-ថៃ កម្ពុជា-វៀតណាម និងកម្ពុជា-ឡាវ ឱ្យទំនាក់ទំនងជាមួយបណ្តាខេត្តជាប់ព្រំដែនប្រទេសទាំងនេះ។<br>- សូមឱ្យស្ថានទូត កុងស៊ុល និងមន្ត្រីក្រសួងការងារ ធ្វើការអប់រំចំពោះពលករ ពលការនី ដែលត្រូវវិលត្រឡប់ឱ្យបានទទួលនូវការយល់ដឹងអំពីការអនុវត្តវិធានការផាកពិន័យ។<br>- បន្តផ្តល់សម្ភារសម្រាប់ធ្វើចត្តាឡីស័ក និងប្រាក់ឧបត្ថម្ភ ២ម៉ឺនរៀលក្នុងមួយថ្ងៃ។<br>- ត្រូវធ្វើបទសម្ភាសន៍ជាមួយប្រជាពលរដ្ឋដែលចូលមកក្នុងប្រទេសទាំងអស់ ដើម្បីស្វែងរកទិន្នន័យថាពួកគេបានធ្វើដំណើរឆ្លងកាត់ព្រំដែន និងតាមកន្លែងណាខ្លះ។<br>- សូមបណ្តាស្ថាប័នសារព័ត៌មានផ្សព្វផ្សាយសារសំឡេងនេះ និងអនុក្រឹត្យលេខ១២៩ អនក្រ.បក ផងដែរ ដើម្បីចែករំលែកព័ត៌មានទាក់ទងនឹងការពង្រឹងការធ្វើចត្តាឡីស័ក។ |
| | ថ្ងៃទី១២ | សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងកម្មវិធីចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ |
| | | សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី ការអនុញ្ញាតឱ្យប្រើប្រាស់ជាផ្លូវការនូវវ៉ាក់សាំង Sinovac's COVID-19 ផលិតដោយសាធារណរដ្ឋប្រជាមានិតចិន និង AstraZeneca's COVID-19 |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងទេសចរណ៍ ស្តីពី ការផ្សព្វផ្សាយខួបមួយឆ្នាំនៃការចូលចតរបស់នាវាទេសចរណ៍ "Westerdam" នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ |

| | | |
|---|---|---|
| ឆ្នាំ: ២០២១ | ថ្ងៃទី១២ | លិខិតអនុញ្ញាតរបស់ក្រសួងសុខាភិបាល ស្តីពី ការប្រើប្រាស់វ៉ាក់សាំងកូវីដ១៩ ដោយអនុញ្ញាតឱ្យប្រើប្រាស់ជាផ្លូវការនូវវ៉ាក់សាំង Sinovac's COVID-19 ផលិតដោយសាធារណរដ្ឋប្រជាមានិតចិន ដែលបានប្រើប្រាស់ប្រកបដោយសុវត្ថិភាពនៅក្នុងប្រទេសចិន និងប្រទេសមួយចំនួនក្នុងលក្ខខណ្ឌនៃការប្រើប្រាស់បន្ទាន់ ( Emergency Use Authorization ) |
| | | លិខិតអនុញ្ញាតរបស់ក្រសួងសុខាភិបាល ស្តីពី ការប្រើប្រាស់វ៉ាក់សាំងកូវីដ១៩ ដោយអនុញ្ញាតឱ្យប្រើប្រាស់ជាផ្លូវការនូវវ៉ាក់សាំង AstraZeneca's COVID-19 ដែលបានប្រើប្រាស់ប្រកបដោយសុវត្ថិភាពនៅក្នុងប្រទេសអង់គ្លេស និងប្រទេសមួយចំនួន ក្នុងលក្ខខណ្ឌនៃការប្រើប្រាស់បន្ទាន់ ( Emergency Use Authorization ) |
| | | សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងទេសចរណ៍ ស្តីពី លទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីទេសចរណ៍អាស៊ានលើកទី២៤ និងកិច្ចប្រជុំពាក់ព័ន្ធ ថ្ងៃទី៤-៥ ខែកុម្ភៈ ឆ្នាំ២០២១។ ដំណោះស្រាយឆ្លើយតបនឹងវិបត្តិកូវីដ១៩៖ ដំណើរការក្នុងការបើកឡើងវិញ៖<br>- ការស្តារភាពជឿជាក់ និងទំនុកចិត្តដោយផ្តោតលើ៖ កម្មវិធីចាក់វ៉ាក់សាំង, គោលការណ៍ណែនាំស្តីពីអនាម័យ និងសុវត្ថិភាព។<br>- ការស្តារឡើងវិញបន្ទាប់ពីវិបត្តិកូវីដ១៩៖ ត្រៀមលក្ខណៈឆ្ពោះទៅអាស៊ានជាគោលដៅទេសចរណ៍តែមួយ រួមមានការបង្កើតផែនការស្តារវិស័យទេសចរណ៍ឡើងវិញបន្ទាប់ពីវិបត្តិកូវីដ១៩, ការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រទេសចរណ៍អាស៊ាន ២០១៦-២០២៥, យុទ្ធសាស្ត្រទីផ្សារទេសចរណ៍អាស៊ាន, កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកលើអ្នកជំនាញទេសចរណ៍, ឯកសារមគ្គុទ្ទេសក៍វិនិយោគទេសចរណ៍អាស៊ាន, សេចក្តីថ្លែងការណ៍អាស៊ានស្តីពីទេសចរណ៍ឌីជីថល, សេចក្តីថ្លែងការណ៍គុំពេញ។ |
| | ថ្ងៃទី១១ | សេចក្តីក្រើនរំឭករបស់ក្រសួងសុខាភិបាល ស្តីពី កម្មវិធីចាក់វ៉ាក់សាំងកូវីដ១៩ ជាបន្ត នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១ និងថ្ងៃបន្តបន្ទាប់ |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារ ស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៥០) |
| | ថ្ងៃទី១០ | សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី កម្មវិធីចាក់វ៉ាក់សាំងកូវីដ១៩ ជាបន្ត នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២១ និងថ្ងៃបន្តបន្ទាប់ |
| | ថ្ងៃទី៩ | សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី ការអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ១៩ នៅក្នុងព្រះរាជាណាចក្រកម្ពុជា |
| | ថ្ងៃទី៨ | សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី ការចាក់វ៉ាក់សាំងកូវីដ១៩ ចាប់ពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ នៅតាមទីតាំងដូចខាងក្រោម៖<br>- មន្ទីរពេទ្យកាល់ម៉ែត៖ ឥស្សរជនជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឬមានឋានៈស្មើ<br>- មន្ទីរពេទ្យព្រះអង្គឌួង៖ ឥស្សរជនជាអនុរដ្ឋលេខាធិការ ឬមានឋានៈស្មើ<br>- មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត៖ ឥស្សរជនជាអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត<br>- មន្ទីរពេទ្យកុមារជាតិ៖ អ្នកសារព័ត៌មាន |
| | ថ្ងៃទី៧ | សម្តេចតេជោនាយករដ្ឋមន្ត្រី អញ្ជើញធ្វើសន្និសីទសារព័ត៌មាន ក្រោយពិធីប្រគល់-ទទួលអំណោយវ៉ាក់សាំងកូវីដ១៩ ពីសាធារណរដ្ឋប្រជាមានិតចិន៖<br>- មូលហេតុដែលសម្តេចសម្រេចមិនចាក់វ៉ាក់សាំងកូវីដ១៩ តាមផែនការនោះ ដោយសារតែទទួលបានលិខិតបញ្ជាក់ផ្លូវការពីស្ថានទូតចិនថា វ៉ាក់សាំងមានប្រសិទ្ធភាពលើអាយុ១៨ ដល់ ៥៩ឆ្នាំ។<br>(តទៅទំព័របន្ទាប់) |

<table>
<tr>
<td rowspan="2">កុម្ភៈ ២០២១</td>
<td rowspan="2">ថ្ងៃទី៧</td>
<td>- មានគម្រោងចរចាដើម្បីទិញវ៉ាក់សាំងកូវីដ១៩ ពីប្រទេសថៃ ដែលនឹងផលិតបាននៅឆ្នាំនេះ និងពិចារណាក្នុងការស្វែងរកវ៉ាក់សាំងកូវីដ១៩ ពីប្រទេសរុស្ស៊ីផងដែរ។<br>- អនុញ្ញាតឱ្យអ្នកសារព័ត៌មាន ជាបុគ្គលអាទិភាពទទួលវ៉ាក់សាំងកូវីដ១៩ផងដែរ។ ក្នុងនោះ សម្តេចតេជោ ក៏បានប្រកាសឱ្យកូនប្រុសទាំង៣ កូនប្រសារ ២របស់សម្តេចរដ្ឋមន្ត្រី ថ្នាក់ដឹកនាំ នាយទាហានជាន់ខ្ពស់ រួមទាំងកូនៗអ្នកធំដែលគ្រប់លក្ខខណ្ឌ ទៅចាក់វ៉ាក់សាំងកូវីដ១៩ ទាំងអស់គ្នា។<br>- ការទទួលបានវ៉ាក់សាំងកូវីដ១៩ នៅថ្ងៃនេះ បង្ហាញឱ្យឃើញការធ្វើការងារយ៉ាងជិតស្និទ្ធជាមួយគ្នារវាងកម្ពុជា និងចិន ដែលកន្លងមកបានក្លាយទៅជាកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ។<br>- សម្តេចតេជោនាយករដ្ឋមន្ត្រី មានបំណងផ្តល់ជូនប្រជាពលរដ្ឋចំនួន៨០% នៃប្រជាពលរដ្ឋសរុបដែលស្មើនឹងចំនួន ១៣លាននាក់ ត្រូវការវ៉ាក់សាំងប្រមាណ ២៦លានដូស។ តែបន្ទាប់ឆ្លងកាត់ការពិភាក្សាជាប់ជាប្រចាំជាមួយគណៈកម្មការកូវ៉ាក់ គឺខាងកូវ៉ាក់ថាគួរផ្តល់ត្រឹម ៦០% ទៅ ៧០% ឬសម្រាប់តែ ១០លាននាក់បានហើយ តែចំពោះសម្តេចតេជោបានបញ្ជាក់ថា សម្តេចនៅតែចង់ផ្តល់ជូនប្រជាពលរដ្ឋអោយបានចំនួន ៨០% នៃប្រជាពលរដ្ឋសរុប។<br>- ប្រភពច្បាស់លាស់នៃវ៉ាក់សាំងគឺចិន ដែលនៅតែជាប្រភពយុទ្ធសាស្ត្រ ដោយសារចិនមានការងាយស្រួលដឹកជញ្ជូន និងសីតុណ្ហភាពងាយស្រួលក្នុងការរក្សាទុក(ដែលចន្លោះតែពី ៦ ដល់ ៨ អង្សារ)<br>- ប្រភពមួយទៀត គឺគណៈកម្មការកូវ៉ាក់ របស់អង្គការសុខភាពពិភពលោក នឹងផ្តល់វ៉ាក់សាំងសម្រាប់ចំនួនប្រជាជន ២០% នៃប្រជាជនសរុប ស្មើនឹង ៣,៥លាននាក់ ឬស្មើនឹង ៧លានដូស ដែលនេះជាច្រកទ្វារមួយទៀត ហើយតាមព័ត៌មាន គឺកូវ៉ាក់មានវ៉ាក់សាំងក្នុងដៃរួចហើយ។<br>- ប្រភពមួយផ្នែកទៀតគឺទទួលបានពីប្រទេសអូស្ត្រាលី ដែលមាន ៣លានដូស។<br>- ដូច្នេះតាមទិន្នន័យវ៉ាក់សាំងពីប្រភពទាំងបីនេះ ទទួលបានវ៉ាក់សាំងសរុប ១១លានដូស។ បើតម្រូវការ ២០លានដូស សម្រាប់ ១០លាននាក់ គឺយើងត្រូវការ ៩លានដូសបន្ថែម តែបើយើងប្រើសម្រាប់ ១៣លាននាក់ គឺយើងនៅខ្វះ ១៥លានដូស។<br>- កម្ពុជា ក៏បានស្នើទៅមិត្តឥណ្ឌា គឺហើយមិត្តឥណ្ឌាអាចផ្តល់ជាការលក់ ១០ម៉ឺនដូស(ដែលវ៉ាក់សាំងនេះផលិតតាមបច្ចេកទេសអង់គ្លេសដែលមានឈ្មោះថា អាស្ត្រាហ្សីណិកា) ដូច្នេះ សូមឱ្យធ្វើការចរចារ ស្នើទិញពី ១ទៅ ៤លានដូស ដែលនឹងអាចចាប់ផ្តើមចរចានៅថ្ងៃស្អែក។<br>- ប្រភពមួយទៀត អាចទិញវ៉ាក់សាំងពីថៃ(អាស្ត្រាហ្សីណិកា) ដែលនឹងផលិតនៅខែឧសភា ខាងមុខនេះ គឺងាយស្រួល និងនៅជិតស្រាប់។ ចំពោះតម្លៃវ៉ាក់សាំងនេះគឺ តម្លៃប្រមាណតែ ៤ដុល្លារអាមេរិកក្នុងមួយដូស ដូច្នេះយើងចំណាយតែ ៤០លានដុល្លារអាមេរិក សម្រាប់ ១០លានដូស ដែលចំនួននេះគឺយើងអាចប្រើថវិកាសប្បុរសធម៌បាន។<br>- សម្តេចតេជោនាយករដ្ឋមន្ត្រី នៅតែអំពាវនាវឱ្យបងប្អូនប្រជាពលរដ្ឋមានការប្រុងប្រយ័ត្ន អនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាលជាប់ជាប្រចាំ។</td>
</tr>
<tr>
<td>សម្តេចតេជោនាយករដ្ឋមន្ត្រី អញ្ជើញទទួលវ៉ាក់សាំងការពារកូវីដ១៩ ចំនួន៦០ម៉ឺនដូស ជំនួយរបស់ចិនក្នុងជំហានដំបូង៖<br>- វ៉ាក់សាំងដែលបានបញ្ជូនមកដល់កម្ពុជានៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២១ មានចំនួន ៦០ម៉ឺនដូស ក្នុងជំហានដំបូង ដោយក្នុងនោះចំនួន ៣០ម៉ឺនដូសសម្រាប់ក្រសួងសុខាភិបាល និង ៣០ម៉ឺនដូសទៀត សម្រាប់ផ្នែកយោធា។<br>- ក្រសួងសុខាភិបាល បានបញ្ជាក់ផងដែរថា អាយុដែលអាចចាក់បានគឺមានពី ១៨ឆ្នាំ ទៅ៥៩ឆ្នាំ ហើយអ្នកដែលមានអាយុលើសពី ៦០ឆ្នាំ ត្រូវរង់ចាំលទ្ធផលនៃការសិក្សាសិន។<br><br>*(តទៅទំព័របន្ទាប់)*</td>
</tr>
</table>

<table>
<tr><td rowspan="4">ខែកុម្ភៈ ២០២១</td><td>ថ្ងៃទី៧</td><td>- ក្នុងពិធីប្រគល់ទទួលនោះ ឯកអគ្គរដ្ឋទូតចិន បានថ្លែងថា ចាប់ពីការផ្ទុះជំងឺកូវីដ១៩ រដ្ឋាភិបាលកម្ពុជា-ចិន បានជួយគ្នាទៅវិញទៅមក ប្រៀបដូចជាពាក្យស្លោកថា «ស្រលាញ់គ្នា ក្នុងគ្រាក្រ ស្គាល់មិត្តល្អក្នុងគ្រាលំបាក»។ ឯកអគ្គរដ្ឋទូតចិន ថ្លែងថាទៀតថា ក្រុមវេជ្ជបណ្ឌិតចិន បានមកបណ្តុះបណ្តាលអំពីរបៀបចាក់វ៉ាក់សាំងកូវីដ១៩ ដល់គ្រូពេទ្យកម្ពុជា ហើយប្រទេសចិននឹងបន្តជួយកម្ពុជាក្នុងការប្រយុទ្ធនឹងកូវីដ១៩ និងផ្តល់ជំនួយដល់កម្ពុជា តាមលទ្ធភាពហូតដល់ឈ្នះជំងឺកូវីដ១៩។<br>- កម្ពុជាទទួលជំនួយវ៉ាក់សាំងកូវីដ១៩ ជំហានទី១ ចំនួន៦០ម៉ឺនដូស ក្នុងចំណោម ១លានដូស ដែលត្រូវទទួលនាពេលបន្ទាប់។ ទោះបីជាកម្ពុជាទប់ស្កាត់បានទ្រង់ទ្រាយធំក៏ដោយ វ៉ាក់សាំងជាតម្រូវការដ៏សំខាន់មួយ ក្នុងការយកឈ្នះជំងឺកូវីដ១៩។ សម្តេច ក៏បានរំឭកដល់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវបន្តយកចិត្តទុកដាក់អនុវត្តវិធានការសុខាភិបាល ដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩។</td></tr>
<tr><td rowspan="2">ថ្ងៃទី៥</td><td>សម្តេចតេជោនាយករដ្ឋមន្ត្រីបានបង្ហោះខ្លឹមសារនៅលើគេហទំព័រហ្វេសប៊ុកផ្លូវការរបស់សម្តេច៖<br>- វ៉ាក់សាំងដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន តាមរយៈក្រសួងការពារជាតិចិនមកកាន់ក្រសួងការពារជាតិកម្ពុជា នឹងដឹកមកដល់កម្ពុជាចំនួន ៦០ម៉ឺនដូស នៅល្ងាចថ្ងៃអាទិត្យ ទី៧ ខែកុម្ភៈ ២០២១ ដែលជាដំណាក់កាលដំបូងនៃជំនួយចំនួន ១លានដូស។<br>- ម៉ោង ៨:៣០នាទី ថ្ងៃទី១០ កុម្ភៈ ២០២១ ដំណើរការចាក់វ៉ាក់សាំងនឹងចាប់ផ្តើមជាផ្លូវការនៅមន្ទីរពេទ្យកាល់ម៉ែត្រដែលសម្តេចតេជោនាយករដ្ឋមន្ត្រីផ្ទាល់ នឹងទទួលមុនគេជាមួយមន្ត្រីជាន់ខ្ពស់ផ្សេងទៀត លើកលែងតែ សម្តេចពិជ័យសេនា ទៀ បាញ់ ដែលបានចាក់វ៉ាក់សាំងនេះរួចហើយ។<br>- ការចាក់វ៉ាក់សាំងនេះនឹងមានការផ្សាយផ្ទាល់។ បន្ទាប់ពីចាក់រួច សម្តេចតេជោនាយករដ្ឋមន្ត្រីនឹងធ្វើសន្និសីទសារព័ត៌មាននៅមន្ទីរពេទ្យកាល់ម៉ែត្រតែម្តង។<br>- សូមជម្រាបជូនបន្ថែមថា ថ្ងៃនេះជាខួបមួយឆ្នាំនៃដំណើរទស្សនកិច្ចរបស់សម្តេចតេជោ ទៅកាន់សាធារណរដ្ឋប្រជាមានិតចិន (៥ កុម្ភៈ ២០២០ - ៥ កុម្ភៈ ២០២១) ដែលជាទស្សនកិច្ចមានអត្ថន័យដ៏ជ្រាលជ្រៅនៃចំណងមិត្តភាព សាមគ្គីភាព ក្នុងដំណាក់កាលដែលប្រទេសចិនកំពុងផ្ទុះឡើងនៃវីរុសកូរ៉ូណា ដែលក្រោយនេះហៅថា ជំងឺកូវីដ១៩ ដែលពេលនោះខ្ញុំបានប្រើពាក្យថា (ស្រឡាញ់គ្នាក្នុងគ្រាក្រ ស្គាល់មិត្តល្អក្នុងគ្រាលំបាក)។<br>- សូមអរគុណ ឯកឧត្តមប្រធានាធិបតី ស៊ី ជីនភីង ឯកឧត្តមនាយករដ្ឋមន្ត្រី លី កឺឈាង និងថ្នាក់ដឹកនាំចិនផ្សេងទៀតដែលបានទទួលរូបខ្ញុំ និងគណៈប្រតិភូ ជាពិសេសបានជួយដល់និស្សិតកម្ពុជាដែលកំពុងសិក្សានៅប្រទេសចិន រាប់ទាំងនៅទីក្រុងវូហានផងឱ្យចៀសផុតពីជំងឺឆ្លង និងទទួលបាននូវការសិក្សាប្រកបដោយសុវត្ថិភាពនៅក្នុងប្រទេសចិនជាមិត្ត។</td></tr>
<tr><td>សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល ស្តីពី ការប្រើប្រាស់វ៉ាក់សាំងកូវីដ១៩ របស់ Beijing Institute of Biological Products ឈ្មោះ SINOPHARM៖<br>- ការចាក់វ៉ាក់សាំងជូនសម្តេចតេជោ និងឥស្សរជនជាន់ខ្ពស់អមដំណើរ ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើង ដែលគ្រោងធ្វើនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ ត្រូវលុបចោល។<br>- ដំណើរការយុទ្ធនាការចាក់វ៉ាក់សាំង នឹងប្រព្រឹត្តទៅសម្រាប់តែអ្នកដែលមានអាយុចាប់ពី ១៨ឆ្នាំ ទៅ ៥៩ឆ្នាំ ទៅតាមក្រុមអាទិភាពដែលមានចែងនៅក្នុងពិធីសារសម្រាប់យុទ្ធនាការចាក់វ៉ាក់សាំងកូវីដ១៩ (ទៅតាមការកែសម្រួលខ្លឹមសារពិធីសារនេះ) ក្រោយពីបានចុះឈ្មោះចាក់វ៉ាក់សាំងដោយស្ម័គ្រចិត្តតាមប្រព័ន្ធអនឡាញដែលនឹងត្រូវដាក់ឱ្យប្រើប្រាស់សប្តាហ៍ក្រោយនេះ ដោយការចាក់វ៉ាក់សាំងនេះនឹងប្រព្រឹត្តទៅនៅតាមមន្ទីរពេទ្យរដ្ឋ (ថ្នាក់ជាតិ ខេត្ត និងស្រុក) ទៅតាមពេលវេលានឹងជម្រាបជូនតាមក្រោយ។</td></tr>
<tr><td>ថ្ងៃទី៤</td><td>សារសំឡេងខ្លីរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី៖<br>- វ៉ាក់សាំងកូវីដ១៩ នឹងមកដល់កម្ពុជានៅថ្ងៃ៧ កុម្ភៈ ខាងមុខនេះហើយ។<br>- ដូចអ្វីដែលសម្តេចបានប្រកាសនារយៈពេលកន្លងមកថា នៅពេលដែលវ៉ាក់សាំងមកដល់ សម្តេចតេជោនាយករដ្ឋមន្ត្រី នឹងអញ្ជើញទៅទទួលវ៉ាក់សាំងនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញផ្ទាល់។</td></tr>
</table>

| | | |
|---|---|---|
| ខែកុម្ភៈ ២០២១ | ថ្ងៃទី៤ | ក្រសួងសុខាភិបាលជម្រាបជូន អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ស្តីពី ការបង្កើនការប្រុងប្រយ័ត្ន និងចាត់វិធានការប្រកបដោយប្រសិទ្ធភាពខ្ពស់ ទប់ស្កាត់ បង្ការការនាំចូលកូវីដ១៩ |
| | | សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល ដោយមានការយល់ព្រមដ៏ខ្ពង់ខ្ពស់ពី សម្តេចតេជោនាយករដ្ឋមន្ត្រី ក្រសួងសុខាភិបាលអនុញ្ញាតឱ្យប្រើប្រាស់ជាផ្លូវការនូវវ៉ាក់សាំង Sinopharm COVID-19 ដែលផលិតដោយវិទ្យាស្ថាន Beijing Institute of Biological Products Co., Ltd នៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានប្រើប្រាស់ប្រកបដោយសុវត្ថិភាពនៅក្នុងប្រទេសចិន និងប្រទេសមួយចំនួនក្នុងលក្ខខណ្ឌនៃការប្រើប្រាស់ជាបន្ទាន់ (Emergency Use Authorization) |
| | | សារពិសេសរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ស្តីពីការអនុវត្តឱ្យបានម៉ឺងម៉ាត់កុំឱ្យមានការនាំចូលកូវីដ១៩៖<br>- រឹតបន្តឹងការធ្វើចរាចរមនុស្សតាមរយៈបងប្អូនពលករ ត្រឡប់ចូលមកក្នុងផ្ទៃប្រទេស។<br>- ការធ្វើចត្តាឡីស័កត្រូវពឹងផ្អែកទាំងស្រុង លើអាជ្ញាធរ និងអភិបាលខេត្តដឹកនាំការងារនេះជាមួយកងកម្លាំងប្រដាប់អាវុធឈរជើង ឱ្យបានហ្មត់ចត់បំផុត។<br>- ដោយមានការផ្ទុះឡើងនៃការឆ្លងក្នុងសហគមន៍នៃប្រទេសវៀតណាម ដែលចាប់ផ្តើមពីភាគខាងជើងដល់ភាគកណ្តាល រហូតមកដល់ពេលនេះមកដល់ភាគខាងត្បូង និងមានមេរោគបំប្លែងថ្មីទៀតផង ដូច្នេះសូមប្រកាសឱ្យបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម ចាប់ពីខេត្តកំពតរហូតដល់ខេត្តរតនគិរី ចាត់វិធានការបន្ទាន់ទប់ស្កាត់កុំឱ្យមានការឆ្លងទៅមករបស់ប្រជាជន ទាំងប្រជាជនកម្ពុជា និងប្រជាជនវៀតណាម។<br>- ដាក់ចេញបទបញ្ជាបន្ទាន់ឱ្យអាជ្ញាធរខេត្តនៅតាមព្រំដែន សហការជាមួយស្ថាប័នពាក់ព័ន្ធ ហើយក្រសួងសុខាភិបាលត្រូវផ្គត់ផ្គង់ទៅបណ្តាខេត្តដែលនៅជាប់ព្រំដែនកម្ពុជា-វៀតណាម។ បណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម ត្រូវពិនិត្យមើលលើកង្វះខាត និងស្នើមកក្រសួងសុខាភិបាល។ ត្រូវសហការជាមួយអាជ្ញាធរខេត្ត និងខេត្តជាប់ព្រំដែនខាងវៀតណាម ដើម្បីជួយទប់ស្កាត់ប្រជាជនដែលឆ្លងពីវៀតណាមមកកម្ពុជា ឬពីកម្ពុជាទៅវៀតណាម និងត្រូវពង្រាយកម្លាំងជាបន្ទាន់ដើម្បីទប់ស្កាត់ការចេញចូល។<br>- បន្តសម្របសម្រួលការដឹកទំនិញទៅមក ដូចដែលបានព្រមព្រៀងគ្នាតាំងពីខែមីនា ឆ្នាំ២០២០។<br>- ដាក់បញ្ជាដោយម៉ឺងម៉ាត់ ឱ្យកម្លាំងប្រដាប់អាវុធ នគរបាលការពារព្រំដែន កងទ័ពជើងគោក ដែលរួមមានបណ្តាភូមិភាគជាប់ព្រំដែនវៀតណាម ចាត់វិធានការជាបន្ទាន់ ដើម្បីរួមជាមួយកម្លាំងប្រដាប់អាវុធផ្សេងទៀត មានទាំងនគរបាល និងអាវុធហត្ថ ដើម្បីត្រួតពិនិត្យឱ្យបានតឹងរឹងបំផុតនៅតាមព្រំដែនកម្ពុជា-វៀតណាម។<br>- ក្រសួងសុខាភិបាលត្រូវពិនិត្យបន្ទាន់ ដើម្បីពិភាក្សាជាមួយខេត្ត រៀបចំតំបន់ធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ និងផ្គត់ផ្គង់ដូចដែលបានធ្វើកន្លងមក។<br>- សូមបណ្តាញផ្សព្វផ្សាយ ធ្វើការផ្សាយសារសំឡេងនេះឱ្យបានទូលំទូលាយបំផុត។ |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារ ស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៤៩) |
| | ថ្ងៃទី៣ | សារាចរណែនាំរបស់ក្រសួងទេសចរណ៍ ស្តីពី ការរៀបចំពង្រឹងគុណភាពផលិតផលទេសចរណ៍ ក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីប្រជាជនចិន និងវៀតណាម ត្រូវនឹងថ្ងៃទី១២-១៤ ខែកុម្ភៈ ឆ្នាំ២០២១ |
| | | សេចក្តីជូនដំណឹងរបស់រដ្ឋបាលរាជធានីភ្នំពេញ ស្តីពី ការរៀបចំសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីចិន និងវៀតណាម |
| | ថ្ងៃទី១ | សេចក្តីណែនាំរបស់ក្រសួងសុខាភិបាល ស្តីពី ការការពារការចម្លងជំងឺកូវីដ១៩ ក្នុងអំឡុងពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ និងពិធីសែនដូនតាផ្សេងៗ |

| | | |
|---|---|---|
| ឆ្នាំ ២០២១ | ថ្ងៃទី២៩ | រដ្ឋមន្ត្រីក្រសួងសុខាភិបាលជម្រាបមកឱសថការីទទួលខុសត្រូវបច្ចេកទេសតាមឱសថស្ថាន-ឱសថស្ថានរង ស្តីពី ការសហការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩ នៅតាមឱសថស្ថានរង នៅកម្ពុជា។ |
| | ថ្ងៃទី២៦ | សម្តេចតេជោនាយករដ្ឋមន្ត្រី ប្រកាសបន្តកាត់បៀវត្សរ៍ទាំងអស់ក្រោយការបង់ពន្ធរយៈពេល ៧ខែទៀត ជូនទៅក្រសួងសុខាភិបាលដោយចាប់ពីខែកុម្ភៈឆ្នាំ២០២១ ដល់ខែសីហា ឆ្នាំ២០២១។ បៀវត្សរ៍របស់សម្តេចតេជោនាយករដ្ឋមន្ត្រី គឺ១០លានរៀល/ខែ ត្រូវបង់ពន្ធ ៩១០.០០០រៀល/ខែ និងប្រគល់ជូនក្រសួងសុខាភិបាល ៩.០៩០.០០០រៀល/ខែ សរុប ៧ខែ ចំនួន ៦៣.៦៣០.០០០រៀល។ |
| | | ក្រសួងសុខាភិបាល ជម្រាបជូនអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ស្តីពីការពង្រឹងការអនុវត្តវិធានការការពារការចម្លងជំងឺកូវីដ១៩ នៅតាមពិធីបុណ្យផ្សេងៗ និងពិធីរៀបអាពាហ៍ពិពាហ៍។ |
| | ថ្ងៃទី២២ | សារាចរណែនាំរបស់ក្រសួងទេសចរណ៍ ស្តីពី ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធចុះបញ្ជីឈ្មោះភ្ញៀវទេសចរតាមប្រព័ន្ធ Telegram BOT ដល់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ទូទាំងប្រទេស |
| | ថ្ងៃទី២១ | សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារ ស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៤៨) |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារ ស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៤៨) |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារ ស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៤៧) |
| | ថ្ងៃទី១៧ | សម្តេចតេជោនាយករដ្ឋមន្ត្រី៖ ដើម្បីបង្កើតនូវជំនឿទុកចិត្តលើវ៉ាក់សាំង និងជំរុញចលនាប្រយុទ្ធនឹងជំងឺកូវីដ១៩ ខ្ញុំព្រះករុណាខ្ញុំសូមប្រកាសថាវ៉ាក់សាំងដែលនឹងចាក់លើកទីមួយ និងមុនគេ គឺរូបខ្ញុំព្រះករុណាខ្ញុំនេះតែម្តង។ ខ្ញុំព្រះករុណាខ្ញុំ ត្រូវតែស្ថិតនៅខ្សែត្រៀមជួរមុខ ដែលជាទម្លាប់ធម្មតារបស់ខ្ញុំព្រះករុណាខ្ញុំរាប់សិបឆ្នាំមកហើយ។ |
| | ថ្ងៃទី១៥ | សារសំឡេងរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ស្តីពី អំណោយវ៉ាក់សាំង Sinopharm របស់ប្រទេសចិន ចំនួន ១លានដូស ជូនមកកម្ពុជា៖<br>- មូលហេតុដែលយើងមានភាពចាំបាច់ដើម្បីប្រើប្រាស់វ៉ាក់សាំងនេះសម្រាប់ការពារ៖ ភាពចាំបាច់នៃការការពារសុខភាពរបស់ប្រជាពលរដ្ឋ; វ៉ាក់សាំងនេះមានការប្រើប្រាស់យ៉ាងទូលំទូលាយរួចមកហើយនៅប្រទេសចិន និងប្រទេសមួយចំនួនផ្សេងទៀតមិនតិចជាង ១០ប្រទេស; លក្ខខណ្ឌនៃការរក្សាទុកសមស្របនឹងសភាពការណ៍របស់កម្ពុជា (២ ដល់ ៨អង្សារ); ភាពងាយស្រួលក្នុងការដឹកជញ្ជូនពីប្រទេសចិន មកកាន់ប្រទេសកម្ពុជា។<br>- អ្នកដែលត្រូវទទួលវ៉ាក់សាំងនេះមុនគេ គឺប្រហែលជាបណ្តាអ្នកដែលនៅជុំវិញខ្លួនសម្តេចតេជោនាយករដ្ឋមន្ត្រី ជាភាពចាំបាច់សម្រាប់ការពារថ្នាក់ដឹកនាំរបស់ប្រទេស ហើយក៏អាចអ្នកដែលនៅជុំវិញព្រះមហាក្សត្រ អ្នកនៅជុំវិញប្រធានព្រឹទ្ធសភា និងប្រធានរដ្ឋសភា។<br>- ត្រូវពិចារណាទិញ ឬស្នើសុំវ៉ាក់សាំងបន្ថែមទៀតពីប្រទេសចិន ឬប្រទេសដទៃ ក្នុងលក្ខខណ្ឌតម្លៃសមស្រប និងលទ្ធភាពនៃការគ្រប់គ្រងវ៉ាក់សាំង។<br>- ចាក់វ៉ាក់សាំងជូនអង្គភាពជួរមុខទាំងអស់ ដែលមុននេះយើងគ្រោងទិញ ១លានដូស ឥឡូវនេះយើងមាន ១លានដូស នៅក្នុងដៃសម្រាប់ការប្រើប្រាស់ហើយ។<br><br>*(តទៅទំព័របន្ទាប់)* |

| | | |
|---|---|---|
| មករា ២០២១ | ថ្ងៃទី១៥ | - ឥឡូវនេះយើងនឹងទទួលបាន Sinopharm ហើយជាបន្ត យើងក៏អាចឈានទៅរកការប្រើប្រាស់ Sinovac ប៉ុន្តែយើងក៏មិនទាត់ចោលនូវការទទួលយកនូវជំនួយផ្សេងៗ ពីប្រទេសដទៃផងដែរ ក្រោមលក្ខខណ្ឌដែលអាចប្រើប្រាស់មានប្រសិទ្ធភាព ការដឹកជញ្ជូន និងស្តុកទុកសមស្រប ស្ថិតក្នុងសមត្ថភាពគ្រប់គ្រងរបស់យើង។<br>- យើងនឹងបន្តការខិតខំដើម្បីចាក់វ៉ាក់សាំងជូនប្រជាជន ប្រហែលជា ១០លាននាក់ ឬរហូតដល់ទៅ ១៣លាននាក់ ប្រសិនមានការតម្រូវឱ្យចាក់វ៉ាក់សាំងរហូតដល់ ៨០ភាគរយ តែក៏អាចនឹងមានការទម្លាក់អត្រាចុះត្រឹម ៦០ ឬ ៧០ភាគរយ។<br>- សូមបងប្អូនជនរួមជាតិស្ងប់អារម្មណ៍ យើងនឹងទទួលបានវ៉ាក់សាំងប្រើប្រាស់ក្នុងពេលឆាប់ៗ។<br>- នឹងរៀបចំឱ្យខ្សែត្រៀមជួរមុខ ជាពិសេសក្រុមគ្រូពេទ្យ គ្រូបង្រៀន កម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ នគរបាលយុត្តិធម៌គ្រប់ផ្នែក បុគ្គលិកអនាម័យទាំងអស់ដែលពាក់ព័ន្ធជាមួយនឹងការផ្តល់សេវា រាប់ទាំងអ្នករត់ម៉ូតូឌុប កង់បី តាក់ស៊ី ទទួលដោយឥតគិតថ្លៃ និងដោយស្ម័គ្រចិត្ត ដែលជាគោលការណ៍ដែលយើងត្រូវតែបន្តនៅក្នុងផែនការវ៉ាក់សាំង។<br>- ជឿជាក់ថាវ៉ាក់សាំងនេះ នឹងអាចសម្រួលឱ្យយើងអាចដោះស្រាយបានបញ្ហាមួយផ្នែក បើទោះបីជាយើងមិនទាន់ដឹងប្រសិទ្ធភាពពិតប្រាកដ មិនមែនគ្រាន់តែវ៉ាក់សាំងរបស់ប្រទេសចិននោះទេ ប៉ុន្តែវ៉ាក់សាំងនៅគ្រប់ប្រទេសទាំងអស់ មិនទាន់ដឹងថាតើមានសុពលភាពរយៈពេលប៉ុន្មានខែ ឆ្នាំ ឬមួយជីវិតឡើយ។ ប៉ុន្តែយ៉ាងណាក៏ដោយ មេដឹកនាំប្រទេសចិនបានចាក់តាំងពីខែតុលា ហើយមានសុខភាពល្អ និងធ្វើដំណើរទស្សនកិច្ចស្ទើរគ្រប់កន្លែង។ ដូច្នេះ បទពិសោធន៍នេះបានផ្តល់ឱ្យយើងនូវជំនឿជឿជាក់ថាវាពុំមានហានិភ័យណាមួយទៅដល់អាយុជីវិតរបស់មនុស្សនោះទេ។<br>- ទោះជាទទួលបានវ៉ាក់សាំងហើយក៏ដោយ ក៏សូមនៅបន្តរក្សានូវ ០៣ការពារ គឺពាក់ម៉ាស លាងដៃ និងរក្សាគម្លាតសុវត្ថិភាព។ |
| | | សេចក្តីជូនដំណឹងរបស់ស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុន ជូនដល់សាធារណៈជន ស្តីពីការដាក់ចេញវិធានការព្រំដែនថ្មីរបស់រដ្ឋាភិបាលជប៉ុន ចាប់ពីម៉ោង ០០:០០ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ រដ្ឋាភិបាលជប៉ុនផ្អាក «ប្រកចូលសម្រាប់ការស្នាក់នៅ» (Residence Track) និង «ប្រកធុរកិច្ច» (Business Track) ដែលកំពុងអនុវត្តជាមួយប្រទេស និងតំបន់ទាំងអស់ រួមទាំងកម្ពុជា |
| | | សេចក្តីក្រើនរំឭកជាថ្មីរបស់លោកជំទាវវេជ្ជបណ្ឌិត ឱ វណ្ណឌីន ស្តីពី អភិក្រម ០៣ការពារ៖<br>- ទី១ គឺពាក់ម៉ាស នៅពេលចេញក្រៅ ឬក្នុងករណីចាំបាច់។<br>- ទី២ គឺត្រូវលាងដៃឱ្យបានញឹកញាប់ ជាមួយសាប៊ូ ឬអាល់កុល ឬជែល។<br>- ទី៣ គឺត្រូវរក្សាគម្លាតសុវត្ថិភាពរវាងបុគ្គលទៅបុគ្គល ពីមួយម៉ែត្រកន្លះឡើង។<br><br>និង អភិក្រម ០៣កុំ៖<br>- ទី១ កុំទៅកន្លែងមានមនុស្សច្រើន។<br>- ទី២ កុំទៅកន្លែងដែលបិទជិតគ្មានខ្យល់ចេញចូល ប្រើម៉ាស៊ីនត្រជាក់ច្រើន។<br>- ទី៣ កុំប៉ះពាល់គ្នា ដូចជាពេលជួបគ្នា កុំចាប់ដៃគ្នា កុំឱបគ្នា កុំកៀកកគ្នា ជាដើម ដោយប្តូរឥរិយាបទនៃការគោរពកិច្ចគ្នាមកជា សំពះ ឱនក្បាល ឬងក់ក្បាលវិញ។ |
| | | សេចក្តីអំពាវនាវជាថ្មីរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ជូនចំពោះបងប្អូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ កុំធ្វើដំណើរវិលមកស្រុកកំណើតវិញដោយលួចលាក់ និងធ្វើខុសពីបម្រាមអាជ្ញាធរថៃ ដោយសូមបន្តស្នាក់នៅក្នុងប្រទេសថៃបន្តទៀត និងចៀសវាងចល័តពីកន្លែងមួយទៅកន្លែងមួយ |
| | ថ្ងៃទី១៣ | សេចក្តីអំពាវនាវសាជាថ្មីរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ជូនដល់ស្ថាប័នសារព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ ចូលរួមប្រយុទ្ធនឹងជំងឺឆ្លងកូវីដ១៩ ដោយធ្វើការផ្សព្វផ្សាយព័ត៌មានអប់រំ និងវិធានការសុវត្ថិភាពរបស់ក្រសួងសុខាភិបាល ជូនប្រជាពលរដ្ឋឱ្យបានយល់ដឹង និងចូលរួមប្រយុទ្ធទប់ស្កាត់ លុបបំបាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ ដែលអាចឆ្លងក្នុងសហគមន៍នោះ |

| | | |
|---|---|---|
| មករា ២០២១ | ថ្ងៃទី១៣ | សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងអប់រំ ស្តីពី ការប្រឈមតាមផ្លូវច្បាប់ ចំពោះគ្រឹះស្ថានសិក្សាណាធ្វេសប្រហែសបង្កការឆ្លងជំងឺកូវីដ១៩។ យោងតាមប្រសាសន៍របស់អ្នកនាំពាក្យក្រសួងអប់រំ អង្គភាពជំនាញថ្នាក់ជាតិ មន្ទីរអប់រំរាជធានី-ខេត្ត ការិយាល័យ ស្រុកខណ្ឌ មានភារកិច្ចគ្រប់គ្រង និងតាមដានតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ ក្នុងករណីគ្រឹះស្ថានសិក្សាណាមួយ ពុំបានអនុវត្តដោយការយកចិត្តទុកដាក់ និងបណ្តាលឱ្យមានការផ្ទុះឆ្លងរាលដាលជំងឺកូវីដ១៩ នៅក្នុងគ្រឹះស្ថានជាយថាហេតុ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាទាំងនោះនឹងប្រឈមវិធានការផ្លូវច្បាប់ និងវិធានការរដ្ឋបាលតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ |
| | ថ្ងៃទី១២ | សេចក្តីជូនប្រកាសព័ត៌មានរបស់ក្រសួងទេសចរណ៍ ស្តីពី ប្រទេសកម្ពុជាៈ ជាប់ចំណាត់ថ្នាក់លេខ ១ លើពិភពលោក ក្នុងការទប់ស្កាត់ជំងឺកូវីដ១៩ |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារ ស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៤៦) |
| | | សេចក្តីជូនដំណឹងរបស់ក្រសួងធម្មការ និងសាសនា បានធ្វើការណែនាំដល់ មន្ទីរធម្មការ និងសាសនារាជធានី-ខេត្ត ថ្នាក់ដឹកនាំសង្ឃនៅតាមទីអារាម ព្រមទាំងប្រជាពុទ្ធបរិស័ទ ស្តីពី ការចូលរួមប្រារព្ធពិធីបុណ្យ «មាឃបូជា» ឱ្យបានអធិកអធម និងត្រូវអនុវត្តវិធានការក្រសួងសុខាភិបាល ដើម្បីទប់ស្កាត់ និងបង្ការការចម្លងជំងឺកូវីដ១៩ |
| | | សេចក្តីក្រើនរំឭករបស់រដ្ឋបាលខេត្តបន្ទាយមានជ័យ ជូនដល់បងប្អូនប្រជាពលរដ្ឋវិលត្រឡប់ពីប្រទេសថៃ ដែលបានបញ្ចប់ការធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ហើយត្រូវទៅកាន់ផ្ទះសម្បែងជួបជុំគ្រួសារ ត្រូវបន្តចូលរួមអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានសុខាភិបាលដោយត្រូវពាក់ ម៉ាស លាងដៃឱ្យបានញឹកញាប់ជាមួយសាប៊ូ អាល់កុល ដែល រក្សាគម្លាតបុគ្គល និងសង្គម ដើម្បីគេចផុតពីការឆ្លងជំងឺកូវីដ១៩នោះ |
| | ថ្ងៃទី១១ | សេចក្តីជូនដំណឹងរបស់ក្រសួងទេសចរណ៍ ស្តីពី ការបើកដំណើរការឡើងវិញនូវគ្រឹះស្ថានអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងមជ្ឈមណ្ឌលវាយតម្លៃក្រោមឱវាទក្រសួងទេសចរណ៍ |
| | | សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងអប់រំ យុវជន និងកីឡា ជាមួយការគាំទ្រពីយូនីសេហ្វ ស្តីពី គោលការណ៍អនុវត្តយុទ្ធនាការ «ការការពារខ្លួនឥលូវនេះ កុំចាំស្អែក» សម្រាប់ការចូលរៀនវិញ ជំរុញឱ្យអនុវត្តឥរិយាបថការពារសុវត្ថិភាព ពីជំងឺកូវីដ១៩ សម្រាប់ឆ្នាំសិក្សា២០២១ ដើម្បីទប់ស្កាត់ និងការពារការរីករាលដាលនៃជំងឺកូវីដ១៩ |
| | ថ្ងៃទី១០ | សារលិខិតរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ថ្លែងក្នុងពិធីបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០២០-២០២១ អះអាងថា ថ្វីត្បិតឆ្នាំនេះ ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាពិភពលោកទាំងមូលកំពុងតែប្រយុទ្ធនឹងជំងឺកូវីដ១៩ និងមិនទាន់មានភាពច្បាស់លាស់ពាក់ព័ន្ធនឹងកូវីដ១៩ យ៉ាងណាក្តី ក៏រាជរដ្ឋាភិបាលកម្ពុជា នៅតែប្រារព្ធពិធីបើកបវេសនកាលឆ្នាំសិក្សាថ្មី២០២០-២០២១ ដ៏មានសារសំខាន់ ក្រោមទស្សនាទានថ្មីគឺ «គន្លងជីវិតថ្មីក្នុងវិស័យអប់រំ» |
| | | សេចក្តីអំពាវនាវរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ជូនដល់ក្រសួង និងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីសហគមន៍ និងប្រជាពលរដ្ឋគ្រប់រូប ស្តីពី ការយកចិត្តទុកដាក់ និងចូលរួមគាំទ្រឱ្យបានខ្លាំងក្លាថែមទៀតក្នុងការអភិវឌ្ឍសាលារៀន ដូចជាការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការគាំទ្រផ្សេងៗតាមគ្រប់លទ្ធភាព ជាពិសេសការចូលរួមសហការរបស់ក្រសួងសុខាភិបាល ក្នុងការធានានូវសុវត្ថិភាពសុខភាព ការអប់រំអំពីអនាម័យ និងការបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ឱ្យបានម៉ឺងម៉ាត់ ធ្វើយ៉ាងណាទប់ស្កាត់កុំឱ្យមានឆ្លងជំងឺកូវីដ១៩ នៅក្នុងគ្រឹះស្ថានសិក្សា |
| | ថ្ងៃទី៩ | សេចក្តីជូនដំណឹងជាបន្ទាន់របស់ស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុន ពាក់ព័ន្ធនឹងការដាក់ចេញវិធានការព្រំដែនថ្មីរបស់រដ្ឋាភិបាលជប៉ុនពាក់ព័ន្ធនឹងកម្ពុជា |

<table>
<tr><td rowspan="8">មករា ២០២១</td><td rowspan="4">ថ្ងៃទី៨</td><td>សេចក្តីណែនាំរបស់ក្រសួងអប់រំ ស្តីពី ការអនុវត្តកម្មវិធីសិក្សាបង្រួញ និងកាលវិភាគសិក្សាសម្រាប់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងមត្តេយ្យសិក្សាសហគមន៍ ឆ្នាំសិក្សា ២០២០-២០២១ តាមការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានសិក្សាឡើងវិញក្នុងបរិបទនៃជំងឺកូវីដ១៩</td></tr>
<tr><td>សេចក្តីណែនាំរបស់ក្រសួងអប់រំ ស្តីពី ការអនុវត្តកម្មវិធីសិក្សាបង្រួញ និងកាលវិភាគសិក្សាសម្រាប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ ឆ្នាំសិក្សា២០២០-២០២១ តាមការអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដា (SOP) សម្រាប់ដំណើរការគ្រឹះស្ថានសិក្សាឡើងវិញក្នុងបរិបទ នៃជំងឺកូវីដ១៩</td></tr>
<tr><td>ក្រុមការងារទទួលបន្ទុកការចរចា និងការពិគ្រោះយោបល់ទិញវ៉ាក់សាំងបង្ការជំងឺកូវីដ១៩ នៅព្រឹកថ្ងៃទី៨ ខែមករា ឆ្នាំ២០២១ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានដឹកនាំកិច្ចប្រជុំលើកទី១ នៃក្រុមការងារអន្តរក្រសួងទទួលបន្ទុកការចរចា និងការពិគ្រោះយោបល់ទិញវ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ពាក់ព័ន្ធនឹងការកំណត់គោលការណ៍ទិញ និងបែងចែក ព្រមទាំងបរិមាណវ៉ាក់សាំង ទាំងសម្រាប់ការប្រើប្រាស់ក្នុងករណីបន្ទាន់ (Emergency Use) និងទាំងសម្រាប់ការប្រើប្រាស់ទូទៅ (General Vaccine Roll Out)។</td></tr>
<tr><td>សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ការអនុវត្តវិធានការសុវត្ថិភាពសិក្សាក្នុងបរិវេសនកាលឆ្នាំសិក្សា២០២០-២០២១ សម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ</td></tr>
<tr><td>ថ្ងៃទី៦</td><td>កិច្ចប្រជុំរបស់ក្រសួងទេសចរណ៍លើសេចក្តីសម្រេច ស្តីពី ការកែសម្រួលសមាសភាព និងភារកិច្ចអនុក្រុមការងារ ដើម្បីជំរុញ និងតាមដានការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍ជំហានទី១ ចំណុះឱ្យក្រុមការងារជំរុញ និងលើកស្ទួយវិស័យទេសចរណ៍ក្នុងដំណាក់កាលវិបត្តិ និងក្រោយវិបត្តិនៃជំងឺកូវីដ១៩៖<br>- ផែនទីចង្អុលផ្លូវស្តីពីផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍ ក្នុងនិងក្រោយវិបត្តិកូវីដ១៩<br>- ប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ សម្រាប់ការរៀបចំព្រឹត្តិការណ៍នៅតាមគោលដៅទេសចរណ៍ទូទាំងប្រទេសកម្ពុជា និង<br>- បច្ចុប្បន្នភាពនៃការងាររៀបចំ Travel Bubble។</td></tr>
<tr><td>ថ្ងៃទី៥</td><td>សេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពី ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារ ស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៤៥)</td></tr>
<tr><td>ថ្ងៃទី៤</td><td>រាជរដ្ឋាភិបាលកម្ពុជា ប្រគល់អំណោយជូនរដ្ឋាភិបាល និងប្រជាជនប្រទេសនេប៉ាល់ រួមមានម៉ាសចំនួនជាង ២លាន និងបរិក្ខារពេទ្យចំនួន ១២មុខ។</td></tr>
<tr><td>ថ្ងៃទី២</td><td>រដ្ឋមន្ត្រីក្រសួងសុខាភិបាល អញ្ជើញចុះពិនិត្យស្ថានភាពច្រកអន្តរជាតិអូរស្មាច់ និងមណ្ឌលធ្វើចត្តាឡីស័កនៅខេត្តឧត្តរមានជ័យ។</td></tr>
</table>

**ប្រភព៖** សេចក្តីប្រកាសព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជា និងសុន្ទរកថាសម្តេចតេជោនាយករដ្ឋមន្ត្រី